មាត្រា ១ : ត្រូវបានដាក់មន្ត្រីរាជការឋានន្តរស័ក្តិឧត្តមមន្ត្រី នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាលរបស់ក្រសួង ស្ថាប័នឱ្យចូលនិវត្តន៍ក្នុងក្របខ័ណ្ឌមុខងារសាធារណៈដោយរក្សាមុខតំណែងនយោបាយដដែល រហូតមានការសម្រេចជាថ្មីពីរាជរដ្ឋាភិបាល ដូចមាននាមខាងក្រោម:

ល.រ	គោត្តនាម និងនាម	ភេទ	ថ្ងៃខែឆ្នាំកំណើត	មុខតំណែង	ឋានន្តរសក្តិនិងថ្នាក់	ថ្ងៃខែឆ្នាំ ចូលនិវត្តន៍
ក្រសួងពាណិជ្ជកម្ម						
១	ចម ប្រសិទ្ធ	ប	១៥-០៥-១៩៥១	ទេសរដ្ឋមន្ត្រី	ឧត្តមមន្ត្រីថ្នាក់លេខ ១	០១-០៦-២០១១
ក្រសួងអប់រំ យុវជន និងកីឡា						
១	ពិត ចំណាន	ប	២៧-១២-១៩៥១	រដ្ឋលេខាធិការ	ឧត្តមមន្ត្រីថ្នាក់លេខ ១	០១-០១-២០១២
ក្រសួងកិច្ចការនារី						
១	ច័ន្ទ សូរីយ៍	ស	១៤-១១-១៩៥០	រដ្ឋលេខាធិការ	ឧត្តមមន្ត្រីថ្នាក់លេខ ២	០១-១២-២០១០
២	ស៊ី ដេហ៊ើន	ស	១០-០៤-១៩៥០	រដ្ឋលេខាធិការ	ឧត្តមមន្ត្រីថ្នាក់លេខ ៤	០១-០៥-២០១០

មាត្រា ២ : ត្រូវបានដាក់មន្ត្រីរាជការឋានន្តរស័ក្តិឧត្តមមន្ត្រីនៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាលរបស់ក្រសួង ស្ថាប័ន ឱ្យចូលនិវត្តន៍ក្នុងក្របខ័ណ្ឌមុខងារសាធារណៈ ដូចមានរាយនាមខាងក្រោម:

ល.រ	គោត្តនាម និងនាម	ភេទ	ថ្ងៃខែឆ្នាំកំណើត	មុខតំណែង	ឋានន្តរសក្តិនិងថ្នាក់	ថ្ងៃខែឆ្នាំ ចូលនិវត្តន៍
ក្រសួងព័ត៌មាន						
១	គិត គឹមហួន	ស	១៧-០២-១៩៥០	អគ្គនាយក	ឧត្តមមន្ត្រីថ្នាក់លេខ ១	០១-០៣-២០១០
ក្រសួងបរិស្ថាន						
១	សំ ចំរើន	ប	០១-១២-១៩៥០	ប្រធាននាយកដ្ឋាន	ឧត្តមមន្ត្រីថ្នាក់លេខ ៥	០១-០១-២០១១
ក្រសួងអប់រំ យុវជន និងកីឡា						
១	ហែម សំគុល	ប	២៦-០៧-១៩៥១	អគ្គនាយករង	ឧត្តមមន្ត្រីថ្នាក់លេខ ៣	០១-០៨-២០១១
ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល						
១	គជ ច័ន្ទថា	ប	១៥-០៥-១៩៥១	មន្ត្រីគ្រប់គ្រងរដ្ឋបាល	ឧត្តមមន្ត្រីថ្នាក់លេខ ២	០១-០៦-២០១១
ក្រសួងពាណិជ្ជកម្ម						
១	ស៊ុំ សាញ់	ប	០៧-០៩-១៩៥១	អគ្គាធិការរង	ឧត្តមមន្ត្រីថ្នាក់លេខ ៥	០១-១០-២០១១
២	ទេស អែគដា	ប	០៦-០៣-១៩៥១	អគ្គនាយក	ឧត្តមមន្ត្រីថ្នាក់លេខ ៦	០១-០៤-២០១១

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

មាត្រា ៣ : បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។

មាត្រា ៤ : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៥ : ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

៣រល.១០០៩.៧៦៤

នរោត្តម សីហមុនី

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ,ថ្ងៃទី ១២ ខែ កញ្ញា ឆ្នាំ ២០១០

លេខៈ ៦៧៧ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ,ថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ២០១០

អគ្គលេខាធិការរាជរដ្ឋាភិបាល

[illegible] ជិនអេន

ព្រះរាជក្រឹត្យ

នស/រកត/០៩១០/៧៥០

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ចំពោះ

សប្បុរសជន និងមន្ត្រីនគរបាលជាតិ ចំនួន ០៦រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួនក្នុងការ រួមចំណែកកសាងអាគារសាកលវិទ្យាល័យបាត់ដំបង និងអាគារសាកលវិទ្យាល័យ **ជា ស៊ីម** កំចាយមារ

នូវ

ក. គ្រឿងឥស្សរិយយស មុនីសារាភណ្ឌ ថ្នាក់ មហាសេនា ចំពោះ :

១- ឯកឧត្តមឧកញ៉ា **លី គង់**

២- លោកស្រីឧកញ៉ា **ង៉ា ចន្ទសម្ភារ**

៣- លោកស្រីឧកញ៉ា **ង៉ា ចន្ទនិត្យា**

៤- លោកជំទាវ **ចាន់ នី ឡុច សារ៉េត**

ខ. គ្រឿងឥស្សរិយយស សុវត្ថារា ថ្នាក់ មហាសេនា ចំពោះ :

លោក **នួន ឥន្ទ្រី**

គ. គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ សេនា ចំពោះ :

លោក **ពូន សុខុន្ធី**

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣៤. ១០០៩. ៧៦៥

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១០

លេខៈ ៦៧៨ ច.ល
ចម្លងចេញពីច្បាប់ដើម
រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ ២០១០
ឥស្សរៈអគ្គលេខាធិការរងទីស្តីការគណៈរដ្ឋមន្ត្រី
ស៊ិនកេន

ព្រះរាជក្រឹត្យ

នស/រកត/០៩១០/៧៥១

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រត្តនខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ចំពោះ

មន្ត្រីរាជការ ចំនួន ០៦រូប ដែលបានខិតខំប្រឹងប្រែងបំពេញភារកិច្ច
បម្រើជាតិមាតុភូមិ និងបានរួមចំណែកលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋក្នុងខេត្តបាត់ដំបង

នូវ

ក. គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ ធិបឌិន្ទ ចំពោះ :

១- លោក សាយ ធាន

២- លោក ទ័ត សុគីម

ខ. គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ សេនា ចំពោះ :

១- លោក អ៊ុយ សារឿន

២- លោក អ៊ុយ វ៉ាត់

៣- លោកស្រី ពេន ផល្លា

គ. គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ អស្សប្ញទ្ធិ ចំពោះ :

លោក ចំរើន ណោតនាទីសំរេច

ព្រះហស្តលេខា និងព្រះរាជលញ្ចករ
នរោត្តម សីហមុនី

៣រល.១០០៩.៧៦៦

លេខៈ ៦៧៩ ច.ល
ចម្លងចេញពីច្បាប់ដើម
រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ២០១០
អគ្គលេខាធិការរងរាជរដ្ឋាភិបាល

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១០

ប៉ុន ជនកេន

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ១១៩ អនក្រ.បក

អនុក្រឹត្យ
ស្តីពី
ការកែសម្រួល និងបំពេញបន្ថែមសមាសភាពក្រុមប្រឹក្សាភិបាល នៃវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ ១៨៤ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០០៨ ស្តីពីការកែសម្រួលអគ្គនាយកដ្ឋាននៃក្រសួងទៅជាអគ្គលេខាធិការដ្ឋាន ការដំឡើងរដ្ឋបាលព្រៃឈើ រដ្ឋបាលជលផលឱ្យមានថ្នាក់ស្មើអគ្គនាយកដ្ឋាន ការដំឡើងនាយកដ្ឋានក្សេត្រសាស្ត្រ និងកែលំអដីកសិកម្ម ឱ្យទៅជាអគ្គនាយកដ្ឋានកសិកម្ម និងការកែសម្រួលអគ្គនាយកដ្ឋានចំការកៅស៊ូ ទៅជាអគ្គនាយកដ្ឋានកៅស៊ូស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ ៦៥ អនក្រ.បក ចុះថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ១៩៩៧ ស្តីអំពីការបង្កើតវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា ជាគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ៦៨ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ២០១០ ស្តីអំពីការកែសម្រួល និងបំពេញបន្ថែមមាត្រា ៥ ចំណុច៥.១ នៃអនុក្រឹត្យលេខ ៦៥ អនក្រ.បក ចុះថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ១៩៩៧ ស្តីអំពីការបង្កើតវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា ជាគ្រឹះស្ថានសាធារណៈរដ្ឋបាល
- យោងតាមការចាំបាច់ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

សម្រេច

មាត្រា ១.-

ត្រូវបានកែសម្រួល និងបំពេញបន្ថែមសមាសភាពក្រុមប្រឹក្សាភិបាល នៃវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា ដូចខាងក្រោម:

១-ឯកឧត្តម	លី ផល្លា	ប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានកៅស៊ូ	ប្រធាន
២-លោក	ម៉ែន ស៊ីផាន់	តំណាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ	សមាជិក
៣-លោក	អ៊ីវ វ៉េត	តំណាងទីស្តីការគណៈរដ្ឋមន្ត្រី	សមាជិក
៤-លោក	ប៉ាវ សុផល	តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ	សមាជិក
៥-លោក	យិន សុង	នាយកវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា	សមាជិកស្ងួយប្រវត្តិ
៦-លោក	ម៉ក់ គឹមហុង	តំណាងអ្នកដាំកៅស៊ូ	សមាជិក
៧-លោក	ផេន ភារុន	តំណាងបុគ្គលិកវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា	សមាជិកស្វ័យប្រវត្តិ

មាត្រា ២.-

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៣.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នាយកវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា១ ត្រូវអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០១០

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ ៖ ១៤០ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការផ្ទេរឥណទានថវិកា

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ , ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ , ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ , ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ , ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៨/០២០ , ចុះថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០០៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រង ឆ្នាំ ២០១០
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក , ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ០៦ អនក្រ.បក , ចុះថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០០៣ ស្តីពីការនាយកដ្ឋានហិរញ្ញវត្ថុមូលដ្ឋាននៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក , ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៤ និងអនុក្រឹត្យលេខ ២០ អនក្រ.បក , ចុះថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០០៨ ស្តីពីការបំពេញបន្ថែមនិង កែសំរួលនាយកដ្ឋាន មួយចំនួន នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៣៤ អនក្រ.បក ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតម្លើងទីចាត់ការគយ និងរដ្ឋាករ នាយកដ្ឋានពន្ធដារ និងរតនាគារជាតិ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឱ្យទៅជាអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានរតនាគារជាតិ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ២៣៨ អនក្រ.បក. ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៩ ស្តីពីការបែងចែកចំណាយថវិកាទូទៅរបស់រដ្ឋតាមជំពូក នៃច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០១០
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

សំរេច

មាត្រា១: ត្រូវបានអនុញ្ញាតឱ្យផ្ទេរឥណទានថវិកា ចំនួន ១៣៨ លានរៀល (មួយរយសាមសិបប្រាំបីលានរៀលគត់) ពីជំពូក ០៩ (ចំណាយមិនបានគ្រោងទុក) នៃខ្ទង់ចំណាយមិនទាន់បែងចែក មកជំពូក ៦១ (សេវាខាងក្រៅ) ជូនក្រសួងការពារជាតិ សម្រាប់ការគ្រប់គ្រងឆ្នាំ ២០១០ ។

មាត្រា២: ការបែងចែកឥណទានថវិកាចំណាយផ្ទៃក្នុងជំពូកនេះ តាមគណនី និង អនុគណនី ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សម្រាប់បង់ថ្លៃសេវាកម្មផ្សេងៗ លើការនាំស្ករស ចំនួន ៤.៤០០ តោន នៅកំពង់ផែស្វ័យតខេត្តព្រះសីហនុ ។

មាត្រា៣: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការពារជាតិ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ , ថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០១០

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- ឯកសារ-កាលប្បវត្តិ

បានយកសេចក្តីជំរាបជូន
សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
នាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា

គាត ឈន់
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ១២៧១ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការផ្ទេរឥណទានថវិកា

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៩/០២០ ចុះថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០០៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រង ឆ្នាំ ២០១០
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ០៦ អនក្រ.បក ចុះថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០០៣ ស្តីពីការនាយកដ្ឋានហិរញ្ញវត្ថុមូលដ្ឋាននៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៤ និងអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី ២៥ ខែ មីនា ឆ្នាំ ២០០៨ ស្តីពីការបំពេញបន្ថែមនិង កែសំរួលនាយកដ្ឋាន មួយចំនួន នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៣៤ អនក្រ.បក ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតម្លើងទីចាត់ការគយ និងរដ្ឋាករ នាយកដ្ឋានពន្ធដារ និងរតនាគារជាតិ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឱ្យទៅជាអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានរតនាគារជាតិ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ២៣៨ អនក្រ.បក ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៩ ស្តីពីការបែងចែកចំណាយថវិកាទូទៅរបស់រដ្ឋតាមជំពូក នៃច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០១០
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

<u>សំរេច</u>

<u>មាត្រា១</u>: ត្រូវបានអនុញ្ញាតឱ្យផ្ទេរឥណទានថវិកាចំនួន ៣.១៨៥.៨០០.០០០ រៀល (បីពាន់មួយរយប៉ែតសិបប្រាំលានប្រាំបីរយពាន់រៀលគត់) ពីជំពូក ០៩ (ចំណាយមិនបានគ្រោងទុក) នៃខ្ទង់ចំណាយមិនទាន់បែងចែកមកជំពូក ៦៥ (ឧបត្ថម្ភកធន និងជំនួយសង្គម) ជូនក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សម្រាប់ការគ្រប់គ្រងឆ្នាំ ២០១០ ។

<u>មាត្រា២</u>: ការបែងចែកឥណទានថវិកាចំណាយផ្ទៃក្នុងជំពូកនេះ តាមគណនី និង អនុគណនី ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដើម្បីបង់ភាគទាន ០,៣ % សម្រាប់ហានិភ័យការងារពីខែមករា ដល់ ខែ វិច្ឆិកា ឆ្នាំ ២០០៩ ជូនដល់សហគ្រាសវិស័យកាត់ដេរ និង ស្បែកជើង ។

<u>មាត្រា៣</u>: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ , ថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១០

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

<u>កន្លែងទទួល</u>

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- ឯកសារ-កាលប្បវត្តិ

បានយកសេចក្តីជំរាបជូន
សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
នាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា

គាត ឈន់
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៩៧១ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា ១ : ត្រូវបានបំពាក់ **មេដាយមុនីសារាភ័ណ្ឌ** ថ្នាក់ **ធិបឌិន្ទ** ជូនអស់លោកជាអ្នកសម្របសម្រួល នៃអង្គការទស្សនៈពិភពលោកចំនួន ០២ រូប ដែលបានជួយសម្របសម្រួលក្នុងការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធនានា នៅស្រុកសំឡូត ខេត្តបាត់ដំបង ទទួលបានលទ្ធផលល្អប្រសើរ ដូចមានរាយនាមខាងក្រោម :

១-លោក **អ៊ុក សារឿន** ប្រធានប្រតិបត្តិខេត្តបាត់ដំបង នៃអង្គការទស្សនៈពិភពលោកកម្ពុជា
២-អ្នកស្រី **ហ៊ឹម ពិសី** ប្រធានកម្មវិធីអភិវឌ្ឍន៍តំបន់សំឡូត នៃអង្គការទស្សនៈពិភពលោកកម្ពុជា

មាត្រា ២ : រដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែកញ្ញា ឆ្នាំ ២០១០

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល
- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ១ និងមាត្រា ២*
- *រាជកិច្ច*
- *ឯកសារ កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៩៧៧ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ អភិបាលនៃគណៈអភិបាលខេត្តកណ្តាល

សម្រេច

មាត្រា ១.-

ត្រូវបានបំពាក់ មេដាយមុនីសារាភ័ណ្ឌ តាមលំដាប់ថ្នាក់ ប្រគេនព្រះសង្ឃ និងជូនមន្ត្រីរាជការ ចំនួន ០៥រូប ដែលបានបរិច្ចាគកម្លាំងកាយ-ចិត្ត ព្រមទាំងធនធាន ចូលរួមកសាងសមិទ្ធផលនានា លើវិស័យព្រះពុទ្ធសាសនា រួមមាន ព្រះវិហារ ហោត្រៃ និងខ្លោងទ្វារ ស្ថិតនៅវត្តពោធិមាស ឃុំពាមឧកញ៉ាអុង ស្រុកល្វាឯម ខេត្តកណ្តាល ដូចមានរាយព្រះនាមនិងនាមខាងក្រោម៖

ក-មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ ធិបឌិន្ទ:

- ព្រះតេជគុណ នោគ រស់ ព្រះគ្រូចៅអធិការវត្តពោធិមាស

ខ-មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ អស្សឫទ្ធិ:

១- លោកស្រី ពៅ ស៊ីធុគ្គា អនុប្រធានមន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍ ខេត្តកណ្តាល

២- លោក មាស គីណាក់ អនុប្រធានមន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍ ខេត្តកណ្តាល

៣- លោក គុង វណ្ណារ៉ូ អនុប្រធានមន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍ ខេត្តកណ្តាល

៤- លោកស្រី ឌុយ ធេព ប្រធានការិ. រដ្ឋបាលបុគ្គលិក គណនេយ្យ មន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍ ខេត្តកណ្តាល

មាត្រា ២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង អភិបាលនៃគណៈអភិបាល ខេត្តកណ្តាល ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ … ឆ្នាំ ២០១០

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល:

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៩៧៣ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន

សម្រេច

មាត្រា ១.-

ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ចំនួន ០១គ្រឿង ជូន Mr. Gaku OFUSA លេខាទី២នៃស្ថានឯកអគ្គរាជទូតជប៉ុនប្រចាំនៅព្រះរាជាណាចក្រកម្ពុជា ដែលមានគុណបំណាច់ ក្នុងការចូលរួមចំណែកសាងសង់ស្ពាន តាំងព្រិច ស្ថិតនៅភូមិឆកកណ្តាល ឃុំជៀប ស្រុកទឹកផុស ខេត្តកំពង់ឆ្នាំង ក្រោមជំនួយសប្បុរសពីប្រទេសជប៉ុន សម្រាប់គម្រោងសន្តិសុខមនុស្សជាតិថ្នាក់មូលដ្ឋាន។

មាត្រា ២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន និង អភិបាលនៃគណៈអភិបាលខេត្តកំពង់ឆ្នាំង ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ [illegible] ឆ្នាំ ២០១០

 នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល:
- -ក្រសួងព្រះបរមរាជវាំង
- -អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- -អគ្គលេខាធិការដ្ឋានរដ្ឋសភា
- -អគ្គលេខាធិការរាជរដ្ឋាភិបាល
- -ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- -ដូចមាត្រា១ និងមាត្រា២
- -រាជកិច្ច
- -ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៩៧៤ . អនក្រ . បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ អភិបាលនៃគណៈអភិបាលខេត្តកណ្តាល

សម្រេច

មាត្រា ១.-

ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ជូនសប្បុរសជន ចំនួន ១៨រូប ដែលបានបរិច្ចាគធនធាន ចូលរួមកសាងសមិទ្ធផលនានា លើវិស័យព្រះពុទ្ធសាសនា រួមមាន: ព្រះវិហារ ហោត្រៃ និង ខ្លោងទ្វារ ស្ថិតនៅវត្តពោធិមាស ឃុំពាមឧកញ៉ាអុង ស្រុកល្វាឯម ខេត្តកណ្តាល ដូចមានរាយនាមខាងក្រោម៖

ក-មេដាយមាសស្ថាបនាជាតិ:

១-	ឧបាសិកា	នូ	ច័ន	សប្បុរសជននៅស្រុកល្វាឯម	ថវិកា ១៦.៧៦៩ ដុល្លារ
២-	លោក	ផាត់	សារិន	សប្បុរសជននៅស្រុកអង្គស្នួល	ថវិកា ១២.១០០ ដុល្លារ
៣-	លោក	ឡាយ	ធិ	សប្បុរសជននៅស្រុកល្វាឯម	ថវិកា ១០.៥០០ ដុល្លារ
៤-	លោក	នូ	ប៊ុនហៀង	សប្បុរសជននៅរាជធានីភ្នំពេញ	ថវិកា ១០.៥០០ ដុល្លារ
៥-	លោក	ចៅ	ចាន	សប្បុរសជននៅក្រុងប៉ោយប៉ែត	ថវិកា ១០.០០០ ដុល្លារ
៦-	អ្នកស្រី	អៀ	ស្រីនួច	សប្បុរសជននៅក្រុងតាខ្មៅ	ថវិកា ១០.០០០ ដុល្លារ
៧-	លោក	សុខ	ធី	សប្បុរសជននៅក្រុងតាខ្មៅ	ថវិកា ១០.០០០ ដុល្លារ
៨-	អ្នកស្រី	ហឿង	គេង	សប្បុរសជននៅស្រុកពារាំង	ថវិកា ១០.០០០ ដុល្លារ

ខ-មេដាយប្រាក់ស្ថាបនាជាតិ:

១-	អ្នកស្រី	ពេញ	យ៉ន	សប្បុរសជននៅរាជធានីភ្នំពេញ	ថវិកា ៥.៥០០ ដុល្លារ
២-	អ្នកស្រី	អឿន	សុខជា	សប្បុរសជននៅស្រុកល្វាឯម	ថវិកា ៥.៥០០ ដុល្លារ

គ-មេដាយសំរិទ្ធស្ថាបនាជាតិ:

១-	លោក	ជា	គូ	សប្បុរសជននៅស្រុកល្វាឯម	ថវិកា ២.៥០០ ដុល្លារ
២-	លោក	អ៊ុំ	ខំ	សប្បុរសជននៅស្រុកល្វាឯម	ថវិកា ១.៥០០ ដុល្លារ
៣-	ឧបាសិកា	ទ័ន	ស្រ៊ុន	សប្បុរសជននៅស្រុកល្វាឯម	ថវិកា ១.៥៥០ ដុល្លារ
៤-	លោក	នុត	យន	សប្បុរសជននៅស្រុកល្វាឯម	ថវិកា ១.៥០០ ដុល្លារ
៥-	ឧបាសិកា	អ៊ុំ	សំអាង	សប្បុរសជននៅស្រុកល្វាឯម	ថវិកា ១.១០០ ដុល្លារ
៦-	អ្នកស្រី	ជ័យ	ដល្លី	សប្បុរសជននៅរាជធានីភ្នំពេញ	ថវិកា ១.០០០ ដុល្លារ
៧-	លោក	ថ្លាង	រុន	សប្បុរសជននៅស្រុកល្វាឯម	ថវិកា ១.២០០ ដុល្លារ
៨-	លោក	ចេង	គន្ធី	សប្បុរសជននៅស្រុកល្វាឯម	ថវិកា ១.៣០០ ដុល្លារ

មាត្រា ២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង អភិបាលនៃគណៈអភិបាល ខេត្តកណ្តាល ត្រូវអនុវត្ត អនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១០

នាយករដ្ឋមន្ត្រី

គណៈរដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល:
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៩៧៤ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការជូនគ្រឿងឥស្សរិយយសមុនីសារាភ័ណ្ឌ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ។
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី ។
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា ។
- តាមសំណើររបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

សម្រេច

មាត្រា ១.-

ត្រូវបានបំពាក់ **គ្រឿងឥស្សរិយយសមុនីសារាភ័ណ្ឌ** ថ្នាក់ **អស្សរឫទ្ធិ** ផ្តល់ជូនលោកវរសេនីយ៍ត្រី ឡៀម សឿន អត្តលេខ ០២៨៣០ សប្បុរសជននៅខេត្តតាកែវ ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួនចូលរួមជួយកសាងសមិទ្ធផលនានាក្នុងវិស័យសង្គមកិច្ច ស្ថិតនៅក្នុងស្រុកត្រាំកក់ ខេត្តតាកែវ **ចំណាយអស់ថវិកាសរុបចំនួន ៣០.០៥០ ដុល្លារ ។**

មាត្រា ២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អភិបាលខេត្តតាកែវ និងសាមីខ្លួន ដែលមានឈ្មោះក្នុងមាត្រា១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០១០

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

<u>កន្លែងទទួល :</u>
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៩៣៥ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា ១ .–

ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ផ្តល់ជូនសប្បុរជនចំនួន ២៩ រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួនជួយកសាងសមិទ្ធផលនានាក្នុងវិស័យសង្គមកិច្ច ស្ថិតនៅក្នុងស្រុកត្រាំកក់ ខេត្តតាកែវ ដែលមានរាយនាមដូចខាងក្រោម :

ក. មេដាយមាសស្ថាបនាជាតិចំនួន ២៥ គ្រឿង ផ្តល់ជូន :

១-លោកស្រី **មុត សុជាវី**	សប្បុរសជននៅខេត្តតាកែវ	ថវិកាចំនួន ១១.០០០ ដុល្លារ
២-លោក **សួន សុធា**	សប្បុរសជននៅខេត្តតាកែវ	ថវិកាចំនួន ១០.៥០០ ដុល្លារ
៣-លោក **រស់ ណារ៉េត**	សប្បុរសជននៅខេត្តតាកែវ	ថវិកាចំនួន ១០.៥០០ ដុល្លារ
៤-លោក **ហ៊ូ សាវ៉ាន់**	សប្បុរសជននៅខេត្តតាកែវ	ថវិកាចំនួន ១០.៥០០ ដុល្លារ
៥-លោក **ចេង ធារី**	សប្បុរសជននៅខេត្តតាកែវ	ថវិកាចំនួន ១០.៥០០ ដុល្លារ
៦-លោកស្រី **សោម ពៅ**	សប្បុរសជននៅខេត្តតាកែវ	ថវិកាចំនួន ១០.១០០ ដុល្លារ
៧-លោក **គុប ប៊ុនថន**	សប្បុរសជននៅខេត្តតាកែវ	ថវិកាចំនួន ១០.១០០ ដុល្លារ
៨-លោក **ឌុក ហ៊ិន**	សប្បុរសជននៅខេត្តតាកែវ	ថវិកាចំនួន ១០.១០០ ដុល្លារ
៩-លោក **ណែម ហាច**	សប្បុរសជននៅខេត្តតាកែវ	ថវិកាចំនួន ១០.១០០ ដុល្លារ
១០-លោក **នាយ ញៀង**	សប្បុរសជននៅខេត្តតាកែវ	ថវិកាចំនួន ១០.០៥០ ដុល្លារ

១១-លោក ទ្រី គៀន	សប្បុរសជននៅខេត្តតាកែវ	ថវិកាចំនួន ១០.០៥០ ដុល្លារ
១២-លោក សាន់ គៀន	សប្បុរសជននៅខេត្តតាកែវ	ថវិកាចំនួន ១០.០៥០ ដុល្លារ
១៣-លោក ម៉ុម ជា	សប្បុរសជននៅខេត្តតាកែវ	ថវិកាចំនួន ១០.០៥០ ដុល្លារ
១៤-លោក ឈុប ហាន	សប្បុរសជននៅខេត្តតាកែវ	ថវិកាចំនួន ១០.០៥០ ដុល្លារ
១៥-លោក ចាន់ ម៉ៅ	សប្បុរសជននៅខេត្តតាកែវ	ថវិកាចំនួន ១០.០៥០ ដុល្លារ
១៦-លោក ឌៀប នាង	សប្បុរសជននៅខេត្តតាកែវ	ថវិកាចំនួន ១០.០៥០ ដុល្លារ
១៧-លោក សំ ម៉ុន	សប្បុរសជននៅខេត្តតាកែវ	ថវិកាចំនួន ១០.០៥០ ដុល្លារ
១៨-លោក អ៊ុំ ថាន	សប្បុរសជននៅខេត្តតាកែវ	ថវិកាចំនួន ១០.០៥០ ដុល្លារ
១៩-លោក ខឹម ឌីន	សប្បុរសជននៅខេត្តតាកែវ	ថវិកាចំនួន ១០.០៥០ ដុល្លារ
២០-លោក យ៉េម គួយ	សប្បុរសជននៅខេត្តតាកែវ	ថវិកាចំនួន ១០.០៥០ ដុល្លារ
២១-លោក ឈុប សារិន	សប្បុរសជននៅខេត្តតាកែវ	ថវិកាចំនួន ១០.០៥០ ដុល្លារ
២២-លោក និត សារេត	សប្បុរសជននៅខេត្តតាកែវ	ថវិកាចំនួន ១០.០៥០ ដុល្លារ
២៣-លោក ជ័យ ឧុឌ្ឌី	សប្បុរសជននៅខេត្តតាកែវ	ថវិកាចំនួន ១០.០៥០ ដុល្លារ
២៤-លោកវរសេនីយ៍ត្រី ម៉ុក ម៉ាប់	អត្តលេខ ០៨៥៧៥ សប្បុរសជននៅខេត្តតាកែវ	ថវិកាចំនួន ១០.០៥០ ដុល្លារ
២៥-លោក ហេង ហាក់ហ៊ុយ	សប្បុរសជននៅខេត្តតាកែវ	ថវិកាចំនួន ១០.០៥០ ដុល្លារ

ខ- មេដាយប្រាក់ស្ថាបនាជាតិចំនួន ០៣ គ្រឿង ផ្តល់ជូន :

១-លោក ឆេព គង់	សប្បុរសជននៅខេត្តតាកែវ	ថវិកាចំនួន ៥.០០០ ដុល្លារ
២-លោក លន់ ហួត	សប្បុរសជននៅខេត្តតាកែវ	ថវិកាចំនួន ៥.០០០ ដុល្លារ
៣-លោក ប្រាក់ ម៉ុនធឿន	សប្បុរសជននៅខេត្តតាកែវ	ថវិកាចំនួន ៥.០០០ ដុល្លារ

គ- មេដាយសំរិទ្ធស្ថាបនាជាតិចំនួន ០១ គ្រឿង ផ្តល់ជូន

លោក មាស មួន	សប្បុរសជននៅខេត្តតាកែវ	ថវិកាចំនួន ១.៧៥០ ដុល្លារ

មាត្រា ២ .-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អភិបាលខេត្តតាកែវ និង សាមីខ្លួន ដែលមានឈ្មោះក្នុងមាត្រា១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០១០

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៩៣៣ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា ១ .–

ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ផ្តល់ជូនសប្បុរជនចំនួន ០៣រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួនជួយកសាងអគារមន្ទីរពេទ្យបង្អែក ០១ខ្នង មានទំហំ ១២ម៉ែត្រ គុណ ២១ម៉ែត្រ និងបំពាក់គ្រឿងសង្ហារឹម ស្ថិតនៅក្នុងឃុំត្រពាំងធំខាងជើង ស្រុកត្រាំកក់ ខេត្តតាកែវ ដែលមានរាយនាមដូចខាងក្រោម ៖

១-លោក	**មាស ខេង**	ប្រធានក្រុមហ៊ុន **អ៊ីស្តារ**	ថវិកាចំនួន ១២.៥០០ ដុល្លារ
២-លោកស្រី	**ម៉ូ ទ្វីច**	សប្បុរសជននៅរាជធានីភ្នំពេញ	ថវិកាចំនួន ១២.៥០០ ដុល្លារ
៣-ឧកញ៉ាមហាឧបាសិកា	**ញ៉ឹក ប៊ុនថា**	ឧត្តមប្រឹក្សាសម្តេចអគ្គមហាសង្ឃរាជធិបតី នៃព្រះរាជាណាចក្រកម្ពុជា ប្រធានពុទ្ធិកសមាគមកម្ពុជរដ្ឋ	ថវិកាចំនួន ១០.៩៧០ ដុល្លារ

មាត្រា ២ .–

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អភិបាលខេត្តតាកែវ និង សាមីខ្លួន ដែលមានឈ្មោះក្នុងមាត្រា១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ... ឆ្នាំ ២០១០

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

<u>កន្លែងទទួល</u> ៖
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៩៧៤ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែកក្កដា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែតុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមសំណើរបស់ឯកឧត្តមឧបនាយករដ្ឋមន្ត្រី **ស ខេង**

សម្រេច

មាត្រា ១ : ត្រូវបានបំពាក់មេដាយស្ថាបនាជាតិ**ថ្នាក់មាស** ជូនលោក **ជា ម៉ៅ** សប្បុរសជន ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួនចូលរួមក្នុងការកសាងអាគារសាកលវិទ្យាល័យបាត់ដំបង ។

មាត្រា ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០១០

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៩៧៩ . អនក្រ . បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយសហមេត្រី

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន

សម្រេច

មាត្រា ១.-

ត្រូវបានបំពាក់ មេដាយសហមេត្រី ថ្នាក់ សេនា ចំនួន ០៦គ្រឿង ជូនមន្ត្រីនៃក្រសួងដឹកជញ្ជូនវៀតណាម ដែលមានស្នាដៃល្អក្នុងការរួមចំណែក កសាងហេដ្ឋារចនាសម្ព័ន្ធនៅកម្ពុជា និងជំរុញកិច្ចសហប្រតិបត្តិការ លើវិស័យដឹកជញ្ជូនរវាងប្រទេសទាំងពីរ កម្ពុជា-វៀតណាម ដូចមានរាយនាមខាងក្រោម ៖

1-	Mr.	Pham Thanh Tung	Director General Int'l Cooperation Dept.
2-	Mr.	Nguyen Van Thach	Deputy General Director of Int'l Cooperation Dept.
3-	Ms.	Phan Thi Thu Hien	Deputy director of Legal and Transportation Dept.
4-	Ms.	Kieu Thi Diem	Official Int'l Cooperation Dept.
5-	Mr.	Nguyen Ngoc Thuyen	Principal Official Int'l Cooperation Dept.
6-	Mr.	Le Due Trung	Official Int'l Cooperation Dept.

មាត្រា ២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ [illegible] ឆ្នាំ ២០១០

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល:
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia

Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

Ministry of Industry, Mines and Energy

លេខ : [illegible]

រាជធានីភ្នំពេញ, ថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០១០

ប្រកាសបង្កើតរោងចក្រ

រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម

-បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-បានឃើញប្រកាសលេខ៨២១ឧរថ.ក ឧ.ប្រក ចុះថ្ងៃទី២៧.០៧.២០០៦ របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-យោងពាក្យស្នើសុំរបស់ក្រុមហ៊ុន ហុងចិច ចុះថ្ងៃទី៣១.០៨.២០១០

សម្រេច

ប្រការ១: អនុញ្ញាតឲ្យក្រុមហ៊ុន ហុងចិច តំណាងដោយ លោក LIN,CHENG-CHENG សញ្ជាតិចិន(តៃវ៉ាន់) អាយុ ៤១ឆ្នាំ កាន់លិខិតឆ្លងដែនលេខ 211624463 ចុះថ្ងៃទី០៩.០៩.២០០៤ មានអាសយដ្ឋានបច្ចុប្បន្ន៖ #24-2F1, 32, Road Jian Chon, Shing Jong Village, Taipei,Taiwan ជាម្ចាស់រោងចក្រធ្វើការបង្កើតរោងចក្រ លើមុខសញ្ញា ដូចខាងក្រោម ៖

-ឈ្មោះផលិតផល	លេខចុះបញ្ជីផលិតផល ISIC Code
សម្លៀកបំពាក់	៣២២០

- ផ្លាកឈ្មោះរោងចក្រ ៖ *"ហុងចិច (HONTEX CO., LTD.)"*

-ទីតាំងរោងចក្រ ៖ *"ភូមិព្រៃព្រីងជើង សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ"*

ប្រការ២: -ម្ចាស់រោងចក្រ ត្រូវរៀបចំផែនការចាត់តាំងតម្លើង និង អនុវត្តឲ្យបានគ្រប់គ្រាន់ នូវវិធានការចាំបាច់នានា ក្នុងការត្រួតពិនិត្យគុណភាពផលិតផល តាមមុខសញ្ញាផលិតកម្ម ដែលបានកំណត់ក្នុងប្រការ១ និងត្រូវអនុវត្តតាមបទប្បញ្ញត្តិបច្ចេកទេសទាំងឡាយ ដែលមានជាធរមាន ។

-ម្ចាស់រោងចក្រ មិនត្រូវប្រើប្រាស់ទីតាំង និងមធ្យោបាយនានា របស់រោងចក្រនេះ ធ្វើការផលិតមុខផលិតផលណាផ្សេង ខុសពីមុខសញ្ញាដែលបានកំណត់ក្នុងប្រការ១ ឡើយ ។ ក្នុងករណីដែលម្ចាស់រោងចក្រ មានបំណងបង្កើតផលិតផលថ្មី បន្ថែមលើមុខសញ្ញាដែលបានកំណត់ក្នុងប្រការ១ ត្រូវធ្វើលិខិតជូនដំណឹង និងស្នើសុំចុះបញ្ជីមុខសញ្ញាផលិតកម្មថ្មី នៅអគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

ប្រការ៣: -ម្ចាស់រោងចក្រ ត្រូវគោរពតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ច្បាប់ផ្សេងៗទៀត និងរាល់អនុក្រឹត្យដែលពាក់ព័ន្ធជាមួយច្បាប់ ។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមសេចក្តីសម្រេច របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្នុងការដាក់វិធានការបទប្បញ្ញត្តិផ្សេងៗ និងត្រូវធ្វើសកម្មភាពដោយអនុលោមតាមអណត្តិ និងលក្ខខណ្ឌនៃប្រកាសនេះ ។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមកាតព្វកិច្ចការពារបរិស្ថាន ដែលបានកំណត់ក្នុងច្បាប់ស្តីពី ការការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ដែលប្រកាសឲ្យប្រើដោយ ព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ និងរាល់អនុក្រឹត្យនានា ស្តីពីការការពារបរិស្ថាន របស់ព្រះរាជាណាចក្រកម្ពុជា ។

ប្រការ៤: ម្ចាស់រោងចក្រ អាចគ្រប់គ្រងរោងចក្រដោយខ្លួនឯង ឬប្រគល់សិទ្ធិឲ្យអ្នកដទៃទៀតគ្រប់គ្រងរោងចក្រជំនួសខ្លួនបាន ដោយធ្វើការជូនដំណឹងជាលាយលក្ខអក្សរ មកក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ប៉ុន្តែ ក្នុងករណីណាក៏ដោយ ម្ចាស់រោងចក្រ ត្រូវតែទទួលខុសត្រូវ លើគ្រប់សកម្មភាព នៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួន ចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់ ។

ប្រការ៥: ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវធ្វើទៅតាមលក្ខណៈបច្ចេកទេស ដែលត្រូវបានកំណត់ដោយប្រកាសក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។ ជនណា ដែលគ្មានជំនាញបច្ចេកទេស មិនអាចជួល ឬចាត់ឲ្យមករៀបចំរោងចក្រ បានឡើយ ។

ប្រការ៦: ម្ចាស់រោងចក្រ ត្រូវលើកបង្ហាញផ្លាកឈ្មោះរោងចក្ររបស់ខ្លួន ជាអក្សរខ្មែរមានទំហំធំជាង និងនៅពីលើអក្សរផ្សេងទៀត នៅកន្លែងដែលសាធារណជនងាយមើលឃើញ ពីមុខរោងចក្រ ។ ៸៸.

ប្រការ៧: -មុនចាប់ផ្ដើមដំណើរការរោងចក្រ ម្ចាស់រោងចក្រ ត្រូវជូនដំណឹងឲ្យបានមុនរយៈពេល ១៥ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ពីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅអគ្គនាយកដ្ឋានឧស្សាហកម្ម ។

-វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ នឹងត្រូវចេញឲ្យម្ចាស់រោងចក្រ មានសុពលភាព ០៣ឆ្នាំ តាមលក្ខខណ្ឌ ដូចខាងក្រោម ៖

ក.ម្ចាស់រោងចក្រ បានដាក់ពាក្យស្នើសុំត្រឹមត្រូវ

ខ.ម្ចាស់រោងចក្រ ផ្ដល់ជូនក្រសួងពិនិត្យនូវរបាយការណ៍ និងផែនការផលិតកម្មប្រចាំឆ្នាំ តាមគំរូដែលបានកំណត់ ។

គ.ម្ចាស់រោងចក្រ បង់ប្រាក់ទូទាត់រួចរាល់ នូវកាតព្វកិច្ចបង់កម្រៃសេវាប្បញ្ញត្តិកម្ម រោងចក្រប្រចាំ ០៣ ឆ្នាំ ។

ប្រការ៨: -ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រជាចំហ នៅកន្លែងសមស្រប ណាមួយ ដែលងាយមើលឃើញក្នុងរោងចក្រ របស់ខ្លួន ។

-មុនផុតសុពលភាព ៣០ថ្ងៃ ម្ចាស់រោងចក្រ ត្រូវធ្វើការស្នើសុំពន្យារបន្តសុពលភាពថ្មី នៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដោយបំពេញលក្ខខណ្ឌ ដូចមានចែងក្នុងប្រការ៧ ។

-ក្នុងរយៈពេល ៣០ថ្ងៃ ក្រោយថ្ងៃផុតសុពលភាព នៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ហើយម្ចាស់រោងចក្រ ពុំបានដាក់ពាក្យស្នើសុំពន្យារបន្តសុពលភាពទេនោះ ក្រសួងនឹងធ្វើការដកហូតប្រកាសនេះវិញ ជាស្វ័យប្រវត្តិ ។

ប្រការ៩: -ម្ចាស់រោងចក្រ ត្រូវផ្ដល់ឲ្យបានត្រឹមត្រូវនូវទិន្នន័យ និងរបាយការណ៍ប្រចាំខែ ប្រចាំឆ្នាំ ជាបន្តបន្ទាប់ និងទៀងទាត់ តាមបែបបទ និងទំរង់កំណត់ ដូចមានភ្ជាប់ជាឧបសម្ព័ន្ធ ក្នុងប្រកាសនេះ ។

-របាយការណ៍សង្ខេបប្រចាំខែ ត្រូវផ្ដល់មកឲ្យអគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅក្នុងអំឡុងពេលនៃសប្ដាហ៍ទីមួយ នៃខែបន្ទាប់ នៅរាល់ដំណាច់ខែនីមួយៗ ។

-របាយការណ៍ប្រចាំឆ្នាំ ត្រូវផ្ដល់មកឲ្យអគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅក្នុងអំឡុងពេលនៃសប្ដាហ៍ទីមួយ នៃខែមករា នៃឆ្នាំបន្ទាប់ ។

-ករណីខកខានក្នុងការផ្ដល់ទិន្នន័យព័ត៌មាន តាមការកំណត់ ម្ចាស់រោងចក្រ នឹងត្រូវទទួលទោសប្បញ្ញត្តិ តាមមាត្រា៤៧ នៃច្បាប់ស្ដីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ។

ប្រការ១០: រាល់ផលិតផលជាទំនិញទាំងអស់ ដែលត្រូវចរាចរលើទីផ្សារ ត្រូវមានស្លាកសញ្ញាបញ្ជាក់សំគាល់ច្បាស់លាស់ អំពីអត្តសញ្ញាណនៃទំនិញ ប្រភេទផលិតកម្មស្របតាមបទប្បញ្ញត្តិ សេចក្ដីណែនាំអំពីស្តង់ដារផលិតផល និងការចុះបញ្ជីផលិតផល ។៙

ប្រការ១១: លក្ខខណ្ឌនានា របស់ប្រកាសនេះអាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ។ ប្រកាសនេះ អាចដកហូតស្របតាមមាត្រា ៣៩ នៃច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងតាមលក្ខខណ្ឌទាំងឡាយ នៃប្រកាសនេះ ។

ប្រការ១២: ក្នុងករណីរោងចក្រ ផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល១២ខែ ឬប្រព្រឹត្តល្មើសច្បាប់ ឬល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយ ដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូត ដោយគ្មានសំណងអ្វីឡើយ ។

ប្រការ១៣: -ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ច របស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ក្នុងគោលបំណង អនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា ៣៧ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឲ្យមានប្រសិទ្ធភាពខ្ពស់ ។

-ម្ចាស់រោងចក្រ ត្រូវរាយការណ៍ជូនដំណឹងមកក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ឲ្យបានឆាប់រហ័សអំពីករណីប្រែប្រួលធំៗហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរដល់ដំណើរការប្រព្រឹត្តិទៅធម្មតា របស់រោងចក្រ ។

ប្រការ១៤: ប្រកាសលេខ៨២១ ឧរថ.កឧ.ប្រក ចុះថ្ងៃទី២៧.០៧.២០០៦ របស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ស្តីពីការបង្កើតរោងចក្រ កាត់ដេរសម្លៀកបំពាក់ របស់ក្រុមហ៊ុន ហុងឋិច ត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ១៥: អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពល រាជធានីភ្នំពេញ និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះ តាមមុខការរៀងៗខ្លួន ។

ប្រការ១៦: ប្រកាសនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

ស៊ុយ សែម

ចម្លងជូន:
- ទីស្តីការគណៈរដ្ឋមន្ត្រី
- រាជកិច្ច
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ក្រសួងបរិស្ថាន
- ក្រសួងពាណិជ្ជកម្ម
- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- សាលារាជធានីភ្នំពេញ
  "ដើម្បីជូនជ្រាប"
- ដូចប្រការ១៥ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry, Mines and Energy
លេខ : ៧៦៨ ឧរថ.កឧ.ប្រក

រាជធានីភ្នំពេញ, ថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០១០

ប្រកាសបង្កើតរោងចក្រ

រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
-បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
-បានឃើញប្រកាសលេខ៩៣៧ឧរថ.កឧ.ប្រក ចុះថ្ងៃទី១៨.០៩.២០០៧ របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
-យោងពាក្យស្នើសុំរបស់ក្រុមហ៊ុន អាណា វ៉តធ័រ អេន ស្មាយល័រ ប៊ីវ៉ើរេច ខូអិលធីឌី ចុះថ្ងៃទី៣១.០៨.២០១០

សម្រេច

ប្រការ១: អនុញ្ញាតឲ្យក្រុមហ៊ុន អាណា វ៉តធ័រ អេន ស្មាយល័រ ប៊ីវ៉ើរេច ខូអិលធីឌី តំណាងដោយ លោក PHAM VANLAC សញ្ជាតិវៀតណាម អាយុ ៤៣ឆ្នាំ កាន់លិខិតឆ្លងដែនលេខ A1023611B ចុះថ្ងៃទី ១១.០២.២០០៤ មានអាសយដ្ឋានបច្ចុប្បន្ន៖ No 131/1450 DUONG26/3,P.13.GO.VAP.TP HOCHIMNH ជាម្ចាស់រោងចក្រ ធ្វើការបង្កើតរោងចក្រ លើមុខសញ្ញាដូចខាងក្រោម ៖

-ឈ្មោះផលិតផល	លេខចុះបញ្ជីផលិតផល ISIC Code
ផលិតស្រាបៀរ ទឹកក្រូច និងទឹកបរិសុទ្ធ	៣១៣៣, ៣៩០២, ៣៩០៣

-ផ្លាកឈ្មោះរោងចក្រ ៖ " *អាណា វ៉តធ័រ អេន ស្មាយល័រ ប៊ីវ៉ើរេច ខូអិលធីឌី (ANA WATER AND SMILER BEVERAGE CO., LTD.)*"

-ទីតាំងរោងចក្រ ៖ *"ភូមិត្រកួន និងភូមិត្រពាំងចារ ឃុំក្រឡា និងឃុំអំពិល ស្រុកកំពង់សៀម ខេត្តកំពង់ចាម "*

ប្រការ២: -ម្ចាស់រោងចក្រ ត្រូវរៀបចំផែនការចាត់តាំងតម្លើង និង អនុវត្តឲ្យបានគ្រប់គ្រាន់ នូវវិធានការចាំបាច់នានា ក្នុងការត្រួតពិនិត្យគុណភាពផលិតផល តាមមុខសញ្ញាផលិតកម្ម ដែលបានកំណត់ក្នុងប្រការ១ និងត្រូវអនុវត្តតាមបទប្បញ្ញត្តិបច្ចេកទេសទាំងឡាយ ដែលមានជាធរមាន ។

-ម្ចាស់រោងចក្រ មិនត្រូវប្រើប្រាស់ទីតាំង និងមធ្យោបាយនានា របស់រោងចក្រនេះ ធ្វើការផលិតមុខផលិតផលណាផ្សេង ខុសពីមុខសញ្ញាដែលបានកំណត់ក្នុងប្រការ១ ឡើយ ។ ក្នុងករណីដែលម្ចាស់រោងចក្រ មានបំណងបង្កើតផលិតផលថ្មី បន្ថែមលើមុខសញ្ញាដែលបានកំណត់ក្នុងប្រការ១ ត្រូវធ្វើលិខិតជូនដំណឹង និងស្នើសុំចុះបញ្ជីមុខសញ្ញាផលិតកម្មថ្មី នៅអគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

ប្រការ៣: -ម្ចាស់រោងចក្រ ត្រូវគោរពតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ច្បាប់ផ្សេងៗទៀត និងរាល់អនុក្រឹត្យដែលពាក់ព័ន្ធជាមួយច្បាប់ ។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមសេចក្តីសម្រេច របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្នុងការដាក់វិធានការបទប្បញ្ញត្តិផ្សេងៗ និងត្រូវធ្វើសកម្មភាពដោយអនុលោមតាមអណត្តិ និងលក្ខខណ្ឌនៃប្រកាសនេះ ។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមកាតព្វកិច្ចការពារបរិស្ថាន ដែលបានកំណត់ក្នុងច្បាប់ស្តីពី ការការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ដែលប្រកាសឲ្យប្រើដោយ ព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ និងរាល់អនុក្រឹត្យនានា ស្តីពីការការពារបរិស្ថាន របស់ព្រះរាជាណាចក្រកម្ពុជា ។

ប្រការ៤: ម្ចាស់រោងចក្រ អាចគ្រប់គ្រងរោងចក្រដោយខ្លួនឯង ឬប្រគល់សិទ្ធិឲ្យអ្នកដទៃទៀតគ្រប់គ្រងរោងចក្រជំនួសខ្លួនបាន ដោយធ្វើការជូនដំណឹងជាលាយលក្ខអក្សរ មកក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ប៉ុន្តែ ក្នុងករណីណាក៏ដោយ ម្ចាស់រោងចក្រ ត្រូវតែទទួលខុសត្រូវ លើគ្រប់សកម្មភាព នៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួន ចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់ ។

ប្រការ៥: ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវធ្វើទៅតាមលក្ខណៈបច្ចេកទេស ដែលត្រូវបានកំណត់ដោយប្រកាសក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។ ជនណា ដែលគ្មានជំនាញបច្ចេកទេស មិនអាចជួល ឬចាត់ឲ្យមករៀបចំរោងចក្រ បានឡើយ ។

ប្រការ៦: ម្ចាស់រោងចក្រ ត្រូវលើកបង្ហាញផ្លាកឈ្មោះរោងចក្ររបស់ខ្លួន *ជាអក្សរខ្មែរមានទំហំធំជាង និងនៅ* ពីលើអក្សរផ្សេងទៀត នៅកន្លែងដែលសាធារណជនងាយមើលឃើញ ពីមុខរោងចក្រ ។៚

ប្រការ៧: -មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រ ត្រូវជូនដំណឹងឲ្យបានមុនរយៈពេល ១៥ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ពីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅអគ្គនាយកដ្ឋានឧស្សាហកម្ម ។

-វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ នឹងត្រូវចេញឲ្យម្ចាស់រោងចក្រ មានសុពលភាព ០៣ឆ្នាំ តាមលក្ខខណ្ឌ ដូចខាងក្រោម ៖

ក.ម្ចាស់រោងចក្រ បានដាក់ពាក្យស្នើសុំត្រឹមត្រូវ

ខ.ម្ចាស់រោងចក្រ ផ្តល់ជូនក្រសួងពិនិត្យនូវរបាយការណ៍ និងផែនការផលិតកម្មប្រចាំឆ្នាំ តាមគំរូដែលបានកំណត់ ។

គ.ម្ចាស់រោងចក្រ បង់ប្រាក់ទូទាត់រួចរាល់ នូវកាតព្វកិច្ចបង់កម្រៃសេវាប្បញ្ញត្តិកម្ម រោងចក្រប្រចាំ ០៣ ឆ្នាំ ។

ប្រការ៨: -ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រជាចំហ នៅកន្លែងសមស្របណាមួយ ដែលងាយមើលឃើញក្នុងរោងចក្រ របស់ខ្លួន ។

-មុនផុតសុពលភាព ៣០ថ្ងៃ ម្ចាស់រោងចក្រ ត្រូវធ្វើការស្នើសុំពន្យារបន្តសុពលភាពថ្មី នៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដោយបំពេញលក្ខខណ្ឌ ដូចមានចែងក្នុងប្រការ៧ ។

-ក្នុងរយៈពេល ៣០ថ្ងៃ ក្រោយថ្ងៃផុតសុពលភាព នៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ហើយម្ចាស់រោងចក្រ ពុំបានដាក់ពាក្យស្នើសុំពន្យារបន្តសុពលភាពទេនោះ ក្រសួងនឹងធ្វើការដកហូតប្រកាសនេះវិញ ជាស្វ័យប្រវត្តិ ។

ប្រការ៩: -ម្ចាស់រោងចក្រ ត្រូវផ្តល់ឲ្យបានត្រឹមត្រូវនូវទិន្នន័យ និងរបាយការណ៍ប្រចាំខែ ប្រចាំឆ្នាំ ជាបន្តបន្ទាប់ និងទៀងទាត់ តាមបែបបទ និងទំរង់កំណត់ ដូចមានភ្ជាប់ជាឧបសម្ព័ន្ធ ក្នុងប្រកាសនេះ ។

-របាយការណ៍សង្ខេបប្រចាំខែ ត្រូវផ្តល់មកឲ្យអគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅក្នុងអំឡុងពេលនៃសប្តាហ៍ទីមួយ នៃខែបន្ទាប់ នៅរាល់ដំណាច់ខែនីមួយៗ ។

-របាយការណ៍ប្រចាំឆ្នាំ ត្រូវផ្តល់មកឲ្យអគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅក្នុងអំឡុងពេលនៃសប្តាហ៍ទីមួយ នៃខែមករា នៃឆ្នាំបន្ទាប់ ។

-ករណីខកខានក្នុងការផ្តល់ទិន្នន័យព័ត៌មាន តាមការកំណត់ ម្ចាស់រោងចក្រ នឹងត្រូវទទួលទោសប្បញ្ញត្តិ តាមមាត្រា៤៧ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ។

ប្រការ១០: រាល់ផលិតផលជាទំនិញទាំងអស់ ដែលត្រូវចែកចរលើទីផ្សារ ត្រូវមានស្លាកសញ្ញាបញ្ជាក់សំគាល់ច្បាស់លាស់ អំពីអត្តសញ្ញាណនៃទំនិញ ប្រភេទផលិតកម្មស្របតាមបទប្បញ្ញត្តិ សេចក្តីណែនាំអំពីស្តង់ដារផលិតផល និងការចុះបញ្ជីផលិតផល ។

ប្រការ១១: លក្ខខណ្ឌនានា របស់ប្រកាសនេះអាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ។ ប្រកាសនេះ អាចដកហូតស្របតាមមាត្រា ៣៩ នៃច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងតាមលក្ខខណ្ឌទាំងឡាយ នៃប្រកាសនេះ ។

ប្រការ១២: ក្នុងករណីរោងចក្រ ផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល១២ខែ ឬប្រព្រឹត្តល្មើសច្បាប់ ឬល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយ ដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូត ដោយគ្មានសំណងអ្វីឡើយ ។

ប្រការ១៣: -ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ច របស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ក្នុងគោលបំណង អនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា ៣៧ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឲ្យមានប្រសិទ្ធភាពខ្ពស់ ។

-ម្ចាស់រោងចក្រ ត្រូវរាយការណ៍ជូនដំណឹងមកក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ឲ្យបានទាប់រហ័សអំពីករណីប្រែប្រួលធំៗហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរដល់ដំណើរការប្រព្រឹត្តិទៅធម្មតា របស់រោងចក្រ ។

ប្រការ១៤: ប្រកាសលេខ៩៣៧ ឧរថ.កឧ.ប្រក ចុះថ្ងៃទី១៨.០៩.២០០៧ របស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ស្តីពីការបង្កើតរោងចក្រ កាត់ដេរសម្លៀកបំពាក់ របស់ក្រុមហ៊ុន អាណា វ៉ៃធ័រ អេនស្មាយល័រ ប៊ីវីរេច ខូអិលធីឌី ត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ១៥: អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពល កំពង់ចាម និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះ តាមមុខការរៀងៗខ្លួន ។

ប្រការ១៦: ប្រកាសនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

ស៊ុយ សែម

<u>ចម្លងជូន:</u>
-ទីស្តីការគណៈរដ្ឋមន្ត្រី
-រាជកិច្ច
-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
-ក្រសួងបរិស្ថាន
-ក្រសួងពាណិជ្ជកម្ម
-ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
-សាលាខេត្តកំពង់ចាម
"ដើម្បីជូនជ្រាប"
-ដូចប្រការ១៥ "ដើម្បីអនុវត្ត"
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសុខាភិបាល

លេខ ០៩៤ ...អបស.ប្រជន

លិខិតចូល
ថ្ងៃទី ២៧ ខែ ០៣ ឆ្នាំ 2010

ប្រកាស

ស្តីពី

ការកំណត់ឯកសណ្ឋាន និង ស្លាកសញ្ញាសម្គាល់ថ្មីរបស់មន្ត្រីចត្តាឡីស័ក

*****

រដ្ឋមន្ត្រីក្រសួងសុខាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកប/០១៩៦/០៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានឃើញអនុក្រឹតលេខ ៦៧ អនក្រ-បក ចុះថ្ងៃទី២២ ខែតុលាឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសុខាភិបាល
- បានឃើញប្រកាសលេខ ១៩៣ អបស ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ ១៩៩៨ របស់ក្រសួងសុខាភិបាលស្តីពីការកំណត់តួនាទីភារកិច្ចរបស់សមត្ថកិច្ចចត្តាឡីស័កនៅតាមច្រកទ្វារព្រំដែន
- បានឃើញលិខិតលេខ ២៨០/០៦ អបស.ប្រជន ចុះថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ ២០០៦ របស់ក្រសួងសុខាភិបាលអំពីសេចក្តីណែនាំនៃការអនុវត្តន៍ភារកិច្ចចត្តាឡីស័ក នៅតាមច្រកទ្វារព្រំដែនអន្តរជាតិ ច្រកទ្វារអន្តរជាតិ ដូចដែលមានចែងក្នុងនិយ័តកម្មសុខភាពអន្តរជាតិ ឆ្នាំ ២០០៥ ឧបសម្ព័ន្ធ ១ ផ្នែក "ខ"
- យោងតាមការចាំបាច់របស់ក្រសួងសុខាភិបាល

<u>សម្រេច</u>

ប្រការ ១: កំណត់និងកែលំអ ឯកសណ្ឋាន និង សញ្ញាសម្គាល់សម្រាប់មន្ត្រីចត្តាឡីស័ក ។

ប្រការ ២: ឯកសណ្ឋាន និងសញ្ញាសម្គាល់នេះសម្រាប់ប្រើប្រាស់ក្នុងពេលប្រតិបត្តិការត្រួតពិនិត្យចត្តាឡីស័ក និងក្នុងពិធីផ្លូវការផ្សេងៗទូទាំងព្រះរាជាណាចក្រកម្ពុជា ។/.

ប្រការ៣: ឯកសណ្ឋានសម្រាប់មន្ត្រីចត្តាឡីស័កត្រូវកំណត់យកចំពោះខោគីសាច់ក្រណាត់ឡែនពណ៌ទឹកប៊ិច និងអាវក្រណាត់ឡែន-កាមែល ពណ៌ស ហើយបែងចែកតាមតួនាទីដូចតទៅ :

១. ប្រធាន និង អនុប្រធានការិយាល័យចត្តាឡីស័ក

២. មន្ត្រីបច្ចេកទេសជំនាញ

ប្រការ ៤: ឯកសណ្ឋានរបស់ប្រធាន និង អនុប្រធានការិយាល័យ សម្រាប់បំពេញបេសកកម្មក្នុងប្រតិបត្តិការត្រួតពិនិត្យចត្តាឡីស័ក និងពិធីផ្លូវការផ្សេងៗត្រូវកំណត់ដូចខាងក្រោម :

ក. ចំពោះបុរស

១. អាវដៃខ្លី កបើក ត្រៃស្មាពីរសងខាង ផែកខ្នង មានហោប៉ៅបួន ហោប៉ៅពីរខាងលើ ដេរបត់ផ្នត់កណ្តាល គម្របរាងស្លឹកពោធិ ហោប៉ៅពីរខាង ក្រោមគ្មានផ្នត់កណ្តាល គម្របរាងចតុកោណកែង ឡេវមានត្រារូបព្រះសង្ហារពណ៌មាស ។

២. ខោជើងវែងពណ៌ទឹកប៊ិច ចង្កេះតថ្នេរបង្កប់ជីបភ្លីខាងមុខពីរ មានហោប៉ៅបី ហោប៉ៅខាងក្រោមមួយដេរបង្កប់ មានគម្រប រាង ស្លឹកពោធិ និងហោប៉ៅពីរទៀតនៅចំហៀងដេរបង្កប់តាមថ្នេរ ។

៣. ស្បែកជើងផលិតពីស្បែក ពណ៌ខ្មៅកខ្លី និងស្រោមជើងពណ៌ខ្មៅ ។

៤. ខ្សែក្រវ៉ាត់ស្បែកពណ៌ខ្មៅ ក្បាលខ្សែក្រវ៉ាត់ពណ៌មាស ។

៥. ក្រវ៉ាត់ក ពណ៌ទឹកប៊ិច

ខ. ចំពោះស្ត្រី

១. អាវម៉ូតដូចបុរសដែរ ។

២. ខោម៉ូតដូចបុរស តែគ្មានហោប៉ៅក្រោយ ឬសំពត់ហ្ស៊ីប កាត់ស្រុងក្រោមជង្គង់ ផែកក្រោយ រូតចំហៀង ។

៣. ស្បែកជើងឃ្លុបកខ្លីផលិតពីស្បែកមានកែង ពណ៌ខ្មៅ ស្រោមជើងពណ៌ខ្មៅ ។

៤. ខ្សែក្រវ៉ាត់ស្បែកពណ៌ខ្មៅ ក្បាលខ្សែក្រវ៉ាត់ពណ៌មាស ។

៥. ក្រវ៉ាត់ក ពណ៌ទឹកប៊ិច

ប្រការ ៥: ឯកសណ្ឋានរបស់មន្ត្រីជំនាញសម្រាប់ប្រតិបត្តិការត្រួតពិនិត្យចត្តាឡីស័ក និងចូលរួមក្នុងពិធីផ្លូវការផ្សេងៗត្រូវកំណត់ដូចខាងក្រោម:

ក. ចំពោះបុរស

១. អាវដៃខ្លី ឬដៃវែង កឌុប ត្រៃស្មាពីរសងខាង ហោប៉ៅពីរ ដេរបត់ផ្នត់កណ្តាល គម្របរាងស្លឹកពោធិ កាត់ស្រុងជើង ត្រង់សម្រាប់ដាក់ក្នុងខោ ឬជីពចង្កេះ។

២. ខោ ស្បែកជើង ខ្សែក្រវ៉ាត់ ក្រវ៉ាត់ក ដូចគ្នាក្នុងប្រការ ៤ ចំណុច ក២ ចំណុច ក៣ និងចំណុច ក៤ នៃប្រកាសនេះ ។

ខ. ចំពោះស្ត្រី

១. អាវដៃខ្លី ឬដៃវែង កឌុប ត្រៃស្មាពីរសងខាង ហោប៉ៅពីរ ដេរបត់ផ្នត់កណ្តាល គម្របរាងស្លឹកពោធិ ជីពចង្កេះ ។

២. ខោ និងសំពត់ ហ្ស៊ីប ស្បែកជើង ខ្សែក្រវ៉ាត់ ដូចគ្នាក្នុងប្រការ ៤ ចំណុច ខ២ ចំណុច ខ៣ និងចំណុច ខ៤ នៃប្រកាសនេះ ។

ប្រការ ៦: ចំពោះមួករបស់មន្ត្រីចត្តាឡីស័ក សម្រាប់ប្រើប្រាស់ក្នុងពេលប្រតិបត្តិការត្រួតពិនិត្យចត្តាឡីស័ក ត្រូវកំណត់ដូចខាងក្រោមៈ មួកកាស្កែតផលិតពីក្រណាត់ពណ៌ទឹកប៊ិច ដែលមានផ្នែក ខាងមុខ លើកណ្ដាប់វ៉ែណ្ណ មានភ្ជាប់រូបព្រះសង្ហារពណ៌មាស កំពស់ ៧.៨ មីលីម៉ែត្រ ទទឹង ៦.៨ មីលីម៉ែត្រ ។ ប៉ែកខាងក្រោមនៃជើងមួក និងខាងក្រោមព្រះសង្ហារ មានកណ្ដាប់វ៉ែណ្ណធ្វើពីក្រណាត់ខ្សែនពណ៌ស្លឹកឈើព័ទ្ធជុំវិញខាងក្រោម កណ្ដាប់វ៉ែណ្ណប៉ែកខាងមុខមានក្បាំងពណ៌ខ្មៅ ។ ខាងមុខក្រោមកណ្ដាប់វ៉ែណ្ណមានកម្រងខ្សែរសយពណ៌មាស ដែលនៅខាងចុងខ្សែភ្ជាប់ដោយឡេវព្រះសង្ហារមួយពណ៌មាស ។

មួកកាស្កែតមានបីប្រភេទគឺ :

ចំពោះប្រធាន និងអនុប្រធានការិយាល័យ : លើជាយក្បាំងពណ៌ខ្មៅ មានរចនាដោយបាច់ផ្កាភ្ញីទេស នៅចំកណ្ដាល និងអមដោយ ក្បាច់សន្ទឹងភ្ញីទេសបួនទង ពណ៌មាសទម្រង់ស្នែងក្របី ចុងសងខាងចន្លោះពីជើងមួក ២០ មីលីម៉ែត្រ ។

ចំពោះប្រធានស្នាក់ការត្រួតពិនិត្យចត្តាឡីស័ក : លើជាយក្បាំងពណ៌ខ្មៅ មានរចនាដោយបាច់ផ្កាភ្ញីទេសនៅចំកណ្ដាល និង អមដោយក្បាច់សន្ទឹងភ្ញីទេសពីរទង ពណ៌មាសទម្រង់ស្នែងក្របី ចុងសងខាងចន្លោះពីជើងមួក ៤០ មីលីម៉ែត្រ ។

ចំពោះមន្ត្រីជំនាញត្រួតពិនិត្យចត្តាឡីស័ក : លើជាយក្បាំងពណ៌ខ្មៅ មានវ៉ែណ្ណទំហំ ០៥មីលីម៉ែត្រពណ៌មាសព័ទ្ធវង់ដល់ ជើងមួក ។

ប្រការ ៧: **ស្លាកសញ្ញាសម្គាល់**

ក. ស្លាកសញ្ញាក្រសួងសុខាភិបាល : ផលិតអំពីសាច់ក្រណាត់ប៉ាក់ដោយកុំព្យូទ័រ និងអំបោះសូត្រមានរាងមូល ដែលមានបន្ទាត់ផ្ចិតទំហំ ៦ សង់ទីម៉ែត្រ បិទភ្ជាប់លើដើមដៃអាវខាងឆ្វេង ។

ខ. ស្លាកសញ្ញាចត្តាឡីស័ក : មានរាងមូល ទំហំ ៥ សង់ទីម៉ែត្រ ។ អក្សរពណ៌ទឹកប៊ិចសរសេរថា "MINISTRY OF HEALTH" នៅផ្នែកខាងលើនិង "QUARANTINE SERVICE" នៅផ្នែកខាងក្រោម ដែលខាន់ដោយក្បាច់ផ្កាច័ន្ទពណ៌ទឹកប៊ិចចំនួនពីរ ។ ខាងក្នុងមានរូបយុថ្កា ចង្កូតរថយន្ត ស្លាបយន្តហោះពណ៌លឿងទុំ រូបពស់ពណ៌បៃតងខ្ចីលៀនអណ្ដាតពណ៌ក្រហម ក្បាច់ស្លឹកឈើពណ៌បៃតងខ្ចីចែកជាពីរផ្នែក ព័ទ្ធព័ន្ធរូបខាងក្នុង ។ នៅខាងផ្នែកចុងនៃយុថ្កាមានសរសេរអក្សរថា "ចត្តាឡីស័ក" ពណ៌ទឹកប៊ិច ហើយនៅខាងលើយុថ្កា មានសរសេរអក្សរថា "CDC" ។

គ. ស្លាកសញ្ញាចត្តាឡីស័កសម្រាប់ពាក់លើស្មា :

គ.១ កំណត់យកស្លាកសញ្ញាចត្តាឡីស័កសម្រាប់ប្រធាន និងអនុប្រធានការិយាល័យ

ស្លាកសញ្ញាចត្តាឡីស័កផលិតពីស្ពាន់ពណ៌មាស ទំហំ ៣.៥ សង់ទីម៉ែត្រ ដែលមានរូបយុថ្កា ចង្កូតរថយន្ត ស្លាបយន្តហោះ រូបពស់លៀនអណ្ដាត ភ្ជាប់លើផ្ទាំងក្រណាត់កាម្ម៉ី ពណ៌ទឹកប៊ិច ដែលមានបណ្ដោយប្រវែង ១២.៥ សង់ទីម៉ែត្រ ទទឹងផ្នែកខាងក្រោមប្រវែង៥.៣សង់ទីម៉ែត្រនិងទទឹងផ្នែកខាងលើប្រវែង៤សង់ទីម៉ែត្រ ។ផ្នែកខាងលើមានឡេវពណ៌មាសសញ្ញាក្រសួងសុខាភិបាលមានទំហំ១.៥សង់ទីម៉ែត្រ ។ ផ្នែកខាងក្រោមស្លាកសញ្ញាចត្តាឡីស័ក មានសរសេរអក្សរថា ចត្តាឡីស័កផលិតពីស្ពាន់ពណ៌មាសប្រវែង៣.៥សង់ទីម៉ែត្រនិងហ៊ុមព័ទ្ធដោយស៊ុមពណ៌ទឹកមាស ។ ស្លាកសញ្ញានេះសម្រាប់ពាក់លើស្មាគឺស៊កក្នុងត្រែសងខាងដោយឡេវកឹប ។

គ.២ ស្លាកសញ្ញាចត្តាឡីស័កសម្រាប់មន្ត្រីជំនាញ

គ.២.១ សម្រាប់ប្រធានស្នាក់ការចត្តាឡីស័ក

ស្លាកសញ្ញាចត្តាឡីស័កផលិតពីដែកអ៊ីណុក ទំហំ ៣.៥ សង់ទីម៉ែត្រ ដែលមានរូបយុថ្កា ចង្កូតរថយន្ត ស្លាបយន្តហោះ រូបពស់លៀន អណ្ដាត បិទភ្ជាប់នៅលើផ្ទាំងក្រណាត់កាម្ម៉ី ពណ៌ទឹកប៊ិច ដែលមានបណ្ដោយ ប្រវែង ១២.៥ សង់ទីម៉ែត្រ ៧៥

ទទឹងផ្នែកខាងក្រោមប្រវែង ៥.៣ សង់ទីម៉ែត្រ និងទទឹងផ្នែកខាង លើប្រវែង ៤ សង់ទីម៉ែត្រ ។ ផ្នែកខាងលើមាន ឡេវពណ៌ទឹកប្រាក់សញ្ញាក្រសួងសុខាភិបាលមានទំហំ១.៥សង់ទីម៉ែត្រ។ ផ្នែកខាងក្រោមស្លាកសញ្ញាចត្តាឡីស័កមានសរសេរ អក្សរថា ចត្តាឡីស័ក ផលិតពីដែកអ៊ីណុកប្រវែង ៣.៥ សង់ទីម៉ែត្រ នឹងហ៊ុមព័ទ្ធដោយស៊ុមពណ៌ទឹកប្រាក់។ ស្លាកសញ្ញានេះសម្រាប់ពាក់លើស្មាតីស៊ីកក្នុងគ្រេសងខាងដោយឡេវកឹប ។

ខ.២.២ សម្រាប់មន្ត្រីចត្តាឡីស័ក

ស្លាកសញ្ញាចត្តាឡីស័កផលិតពីដែកអ៊ីណុក ទំហំ ៣.៥ សង់ទីម៉ែត្រ ដែលមានរូបយុថ្កា ចង្កូតរថយន្ត ស្លាបយន្តហោះ រូបពស់លៀនអណ្តាត បិទភ្ជាប់នៅលើផ្ទាំងក្រណាត់កាំម្ទី ពណ៌ទឹកប៊ិច ដែលមានបណ្តោយប្រវែង ១២.៥ សង់ទីម៉ែត្រ ទទឹងផ្នែកខាងក្រោមប្រវែង៥.៣សង់ទីម៉ែត្រនិងទទឹងផ្នែកខាងលើប្រវែង៤ សង់ទីម៉ែត្រ ។ ផ្នែកខាងលើមានឡេវពណ៌ទឹកប្រាក់ សញ្ញាក្រសួងសុខាភិបាលមានទំហំ១.៥សង់ទីម៉ែត្រ ។ ផ្នែកខាងក្រោមស្លាកសញ្ញា ចត្តាឡីស័កមានសរសេរអក្សរថា ចត្តាឡីស័ក ផលិតពីដែកអ៊ីណុកប្រវែង៣.៥សង់ទីម៉ែត្រ។ ស្លាកសញ្ញានេះសម្រាប់ពាក់លើស្មាតីស៊ីកក្នុងគ្រេសងខាង ដោយឡេវកឹប ។

គ. ស្លាកសញ្ញាសំគាល់សម្រាប់ពាក់លើចុងកអាវឆ្វេង ស្តាំមានបីប្រភេទ:

- ប្រធាននិងអនុប្រធានការិយាល័យផលិតពីក្រណាត់ឡែនពណ៌ទឹកប៊ិចមានរាងប្រលេឡូក្រាម បណ្តោយប្រវែង៥.៥សង្ទីម៉ែត្រ ទទឹង៣.៨សង់ទីម៉ែត្រនៅផ្នែកកណ្តាលមានរូបសញ្ញាចត្តាឡីស័កទំហំ១.៥សង់ទីម៉ែត្រធ្វើពីស្ពាន់ ហើយហ៊ុមព័ទ្ធដោយស៊ុមពណ៌មាស ផ្នែកខាងក្រោមមានម្ជុលខ្ទាស់សម្រាប់ភ្ជាប់ស្លាកនឹងចុងកអាវទាំងសង ខាង ។
- ប្រធានទីស្នាក់ការចត្តាឡីស័ក ផលិតពីក្រណាត់ឡែនពណ៌ទឹកប៊ិច មានរាងប្រលេឡូក្រាម បណ្តោយប្រវែង៥.៥សង់ទីម៉ែត្រ ទទឹង៣.៨សង់ទីម៉ែត្រនៅផ្នែកកណ្តាលមានរូបសញ្ញាចត្តាឡីស័កទំហំ១.៥សង់ទីម៉ែត្រធ្វើពីដែកអ៊ីណុក ហើយហ៊ុមព័ទ្ធដោយស៊ុមពណ៌ទឹកប្រាក់ ផ្នែកខាងក្រោមមានម្ជុលខ្ទាស់សម្រាប់ភ្ជាប់ស្លាកនឹងចុងកអាវទាំង សងខាង ។
- មន្ត្រីជំនាញផលិតពីក្រណាត់ឡែនពណ៌ទឹកប៊ិចមានរាងប្រលេឡូក្រាមបណ្តោយប្រវែង៥.៥សង់ទីម៉ែត្រទទឹង៣.៨សង្ទីម៉ែត្រនៅផ្នែកកណ្តាលមានរូបសញ្ញាចត្តាឡីស័កទំហំ១.៥សង់ទីម៉ែត្រធ្វើពីដែកអ៊ីណុក ផ្នែកខាងក្រោមមានម្ជុលខ្ទាស់សម្រាប់ភ្ជាប់ស្លាក នឹង ចុង កអាវទាំង សងខាង ។

ប្រការ ៨: ស្លាកឈ្មោះ

- ស្លាកឈ្មោះមន្ត្រីដាក់លើហោប៉ៅអាវខាងស្តាំ

កំណត់យកស្លាករាងបួនជ្រុងទ្រវែង ទំហំបណ្តោយប្រវែង ៩ សង់ទីម៉ែត្រ ទទឹង ២.២ សង់ទីម៉ែត្រ ធ្វើអំពីជាតិជ័ររឹងថ្លា ។ ផ្ទៃខាងក្នុង ពណ៌ខៀវព័ទ្ធជុំវិញដោយខ្សែបន្ទាត់ពណ៌ទឹកមាសសម្រាប់ប្រធាន និង អនុប្រធានការិយាល័យនិងពណ៌ទឹកប្រាក់ សម្រាប់មន្ត្រីបិទជិត។

ស្លាកនេះចែកជាពីរផ្នែកគឺ :

- ខាងស្តាំទំហំ ២.៥ សង់ទីម៉ែត្រ គឺជាស្លាកសញ្ញារបស់ចត្តាឡីស័ក
- ឈ្មោះសរសេរជាអក្សរខ្មែរពណ៌ទឹកមាសសម្រាប់ប្រធាន និង អនុប្រធានការិយាល័យ និងពណ៌ទឹកប្រាក់ សម្រាប់មន្ត្រី ។

ប្រការ ៩: របបកំណត់សិទ្ធិប្រើប្រាស់ឯកសណ្ឋាន និងស្លាកសញ្ញាសម្គាល់ត្រូវបានផ្តល់ដល់មន្ត្រីម្នាក់ៗដូចបានកំណត់ក្នុងប្រកាសនេះ ចំនួនពីរ (២) សម្រាប់ សម្រាប់ប្រើប្រាស់ក្នុងរយៈពេលមួយឆ្នាំម្តង ។/

ប្រការ ១០: ប្រធានការិយាល័យចត្តាឡីស័ក មានភារកិច្ចទទួលខុសត្រូវលើការគ្រប់គ្រង ចែកចាយជូនដល់មន្ត្រីម្នាក់ៗ នូវឯកសណ្ឋាន និងសញ្ញាសម្គាល់ដូចមានកំណត់ក្នុងប្រកាសនេះ ។

ប្រការ ១១: ក្នុងពេលបំពេញបេសកកម្មមន្ត្រីចត្តាឡីស័កត្រូវស្លៀកពាក់ឯកសណ្ឋាននិងស្លាកសញ្ញាសម្គាល់ឱ្យបានត្រឹមត្រូវដូចដែលបានកំណត់ក្នុងប្រកាសនេះ ។

ប្រការ១២: ជនណាក្លែងបន្លំស្លៀកពាក់ឯកសណ្ឋាននិងស្លាកសញ្ញាសម្គាល់ចត្តាឡីស័កឬប្រើប្រាស់មិនដូចការកំណត់ក្នុងប្រកាសនេះ ត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន ។

ប្រការ ១៣: ប្រកាស ឬ សេចក្តីសម្រេចទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

ប្រកាសនេះមានអានុភាពអនុវត្តរហូតដល់មានអនុក្រឹត្យស្តីពីការបង្កើត ឯកសណ្ឋាននិងសញ្ញាសម្គាល់របស់មន្ត្រីចត្តាឡីស័កថ្មីមកជំនួស ។

ប្រការ ១៤: ខុទ្ទកាល័យក្រសួងសុខាភិបាល អគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានបច្ចេកទេសសុខាភិបាល អគ្គាធិការដ្ឋាន ប្រធាននាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លង គ្រប់នាយកដ្ឋាន ប្រធានការិយាល័យចត្តាឡីស័ក ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះឱ្យមានប្រសិទ្ធភាពតាមភារៈកិច្ចរៀងៗខ្លួនចាប់ពី ថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី [illegible] ខែ[illegible] ឆ្នាំ២០១០

ម៉ម_ប៊ុនហេង

កន្លែងទទួល :

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ
- គ្រប់សាលាខេត្ត-រាជធានី
- ដូចប្រការ ១៤
- ឯកសារ-កាលប្បវត្តិ

១ ២ ៣





១ - ពណ៌មាស ២ - ពណ៌ប្រាក់

១

២

៣



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
៣✻៤

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

លេខ ០១៥ ស.អ.យ.

រាជធានីភ្នំពេញ, ថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០១០

លិខិតចូល
ថ្ងៃទី១៧...ខែកញ្ញា.ឆ្នាំ2010.

សារាចរណែនាំ
ស្ដីពី
វិធានការដោះស្រាយការទិញ បញ្ចាំ លក់ របបសន្តិសុខសង្គម របស់អតីតយុទ្ធជន និងអតីតមន្ត្រីរាជការស៊ីវិល

ដើម្បីអនុវត្តឱ្យមានប្រសិទ្ធភាពអនុសាសន៍ដ៏ខ្ពង់ខ្ពស់ សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងជាប្រធានសមាគមអតីតយុទ្ធជនកម្ពុជា ថ្លែងនៅក្នុងឱកាសបិទមហាសន្និបាតវិសាមញ្ញ តំណាងទូទាំងប្រទេសរបស់សមាគមអតីតយុទ្ធជនកម្ពុជា និងខួបលើកទី ៣ ទិវាអតីតយុទ្ធជនកម្ពុជាថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០១០ ។

កន្លងទៅ អនុវត្តតាមគោលការណ៍របស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទារាជធានី ខេត្ត បានយកចិត្តទុកដាក់បើកផ្ដល់របបសន្តិសុខសង្គមជូនអតីតយុទ្ធជន និង អតីតមន្ត្រីរាជការស៊ីវិល បានល្អប្រសើរជាបន្តបន្ទាប់ ។ ការទិញ លក់ បញ្ចាំ របបសន្តិសុខសង្គម ត្រូវបានដោះស្រាយ ជាច្រើនករណី ជួយលើកស្ទួយជីវភាពរបស់អតីតយុទ្ធជន និងអតីតមន្ត្រីរាជការស៊ីវិល តាមគោលនយោបាយរបស់រាជរដ្ឋាភិបាលបានត្រឹមត្រូវ ។ ទន្ទឹមនោះ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ពិនិត្យឃើញថា បាតុភាពទិញ លក់ បញ្ចាំ របបសន្តិសុខសង្គម ដោយសារមូលហេតុផ្សេងៗ ដើម្បីដោះស្រាយជីវភាពនៅកើតមាននៅឡើយ ។

ដើម្បីបញ្ចប់បាតុភាពនេះ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ធ្វើការណែនាំអនុវត្តដូចតទៅ :

១-មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទារាជធានី ខេត្ត ត្រូវខិតខំទប់ស្កាត់ លុបបំបាត់ ការទិញ បញ្ចាំ លក់របបសន្តិសុខសង្គមរបស់អតីតយុទ្ធជន និងអតីតមន្ត្រីរាជការស៊ីវិល ។ ត្រូវចាត់ទុករបបសន្តិសុខសង្គម របស់រដ្ឋដែលផ្ដល់ជូនទាំងនេះ ជាសិទ្ធិប្រយោជន៍ស្របច្បាប់របស់អតីតយុទ្ធជន និងអតីតមន្ត្រីរាជការស៊ីវិល ព្រមទាំងគ្រួសារ ដែលមិនអាចដកហូត ឬ លក់ បញ្ចាំ ដើម្បីទូទាត់បំណុលបាន ឡើយ ។ មន្ត្រីរាជការដែលមាន ភារកិច្ចពាក់ព័ន្ធគ្រប់ជាន់ថ្នាក់ មានភារកិច្ចអនុវត្តគោលនយោបាយ និងការពារសិទ្ធិប្រយោជន៍ជូនបងប្អូនឱ្យ បានល្អ ។

២-មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទារាជធានី ខេត្ត ត្រូវធ្វើអធិការកិច្ចផ្ទៀងផ្ទាត់ ឱ្យបានហ្មត់ចត់ លើបញ្ជីបើកផ្ដល់ប្រាក់ប្រចាំខែ និងមនុស្សជាក់ស្ដែង ។ រកឱ្យឃើញករណី ទិញ លក់ បញ្ចាំ របបសន្តិសុខសង្គម ដែលនៅសេសសល់មុនខែ សីហា ឆ្នាំ ២០១០ ។ ធ្វើបញ្ជីឈ្មោះករណីមុខសញ្ញា ដែលលក់បញ្ចាំរបបរបស់ខ្លួន និងបញ្ជីឈ្មោះ អ្នកទិញ ឬទទួលបញ្ចាំរបបសន្តិសុខសង្គមរបស់មុខសញ្ញា ។

៣-មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទារាជធានី ខេត្ត ត្រូវចាត់វិធានការដូចតទៅ :

ក-ត្រូវណែនាំអ្នកទិញ ឱ្យបញ្ឈប់ការប្រកបមុខរបរនេះ ដោយត្រូវប្រគល់សៀវភៅបើកប្រាក់ឧបត្ថម្ភ និងសិទ្ធិបើកប្រាក់ឱ្យទៅមុខសញ្ញាវិញ ។

ខ-ក្នុងករណីដែលអ្នកទិញ លក់ បញ្ចាំ ព្រមសម្របសម្រួលដោយសុំកម្រៃទូទាត់ខ្លះ ត្រូវដោះស្រាយថវិកា ដើម្បីជួយសម្រួលការទូទាត់យករបបមកជូនម្ចាស់ដើមវិញ ។ ករណីនេះ ត្រូវសហការជាមួយសមាគមអតីតយុទ្ធជនកម្ពុជា ឬ ត្រូវប្រើប្រាស់មូលនិធិរបស់សម្តេចអគ្គមហាសេនាបតីតេជោ ដើម្បីសម្រួលការដោះស្រាយករណីនេះ ។

គ-ក្នុងករណីអ្នកទិញរបបសន្តិសុខសង្គម មិនព្រមប្រគល់សិទ្ធិឱ្យម្ចាស់ដើមវិញ ត្រូវចាត់វិធានការដូចតទៅ :

-ពិនិត្យកិច្ចសន្យាទិញ លក់ បញ្ចាំ បើមាន ដើម្បីជួយដោះស្រាយ លោះ យកមកប្រគល់ឱ្យម្ចាស់ដើមវិញ ។

-ក្នុងករណី អ្នកទិញ លក់ បញ្ចាំ មានការកេងប្រវ័ញ្ចហួសហេតុ ហើយរឹងរូស មិនព្រមសម្របសម្រួល ត្រូវចាត់វិធានការតាមច្បាប់ តាមផ្លូវតុលាការ ចំពោះអ្នកទិញ ដើម្បីរឹបយករបបមកជូនសាមីខ្លួនវិញ ។

-ក្នុងករណី អ្នកទិញ លក់ បញ្ចាំ ក្លែងបន្លំអត្តសញ្ញាណ ត្រូវចាត់វិធានការតាមច្បាប់ជាធរមាន ។

ឃ-មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទារាជធានី ខេត្ត មិនត្រូវបើករបបសន្តិសុខសង្គមឱ្យអ្នកទិញ ឬទទួលបញ្ចាំ ជាដាច់ខាត ។

៤-មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទារាជធានី ខេត្ត ត្រូវរៀបចំបញ្ជីឈ្មោះអ្នកទិញ និងទទួលបញ្ចាំឱ្យបានច្បាស់លាស់ ។ ក្នុងករណី ជាមន្ត្រីរាជការរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ឬ សាច់ញាតិប្រកបរបរនេះ ត្រូវចាត់វិធានការពិន័យតាមបទប្បញ្ញត្តិជាធរមាន រឹបអូសរបបសងទៅសាមីជនវិញ និងបណ្តេញចេញពីក្របខណ្ឌរបស់ក្រសួង ។ ក្នុងករណីជាមន្ត្រីរាជការ ឬ ក្រុមគ្រួសារ សាច់ញាតិ នៃក្រសួង ស្ថាប័ន ផ្សេងដែលអនុវត្តរបរនេះ ត្រូវធ្វើរបាយការណ៍ ជូនអាជ្ញាធររាជធានី ខេត្ត និងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដើម្បីស្នើទៅក្រសួង ស្ថាប័នពាក់ព័ន្ធចាត់វិធានការតាមច្បាប់ ។ ក្នុងករណី អ្នកទិញ ឬទទួលបញ្ចាំ ជាប្រជាពលរដ្ឋធម្មតាត្រូវសហការជាមួយអាជ្ញាធរមានសមត្ថកិច្ចដោះស្រាយ ។

៥-អតីតយុទ្ធជន និងអតីតមន្ត្រីរាជការស៊ីវិល គ្រប់ប្រភេទ ដែលកំពុងទទួលរបបសន្តិសុខសង្គមពីរដ្ឋ មិនត្រូវលក់ ឬបញ្ចាំរបបសន្តិសុខសង្គមរបស់ខ្លួនឡើយ ។ ក្នុងករណីមានការលំបាកដោយថាហេតុណាមួយ ត្រូវទំនាក់ទំនងជាមួយមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទារាជធានី ខេត្ត ឬសមាគមរបស់ខ្លួនដើម្បីជួយដោះស្រាយ ។ ក្នុងករណី ដែលបានលក់ ឬបញ្ចាំរបបសន្តិសុខសង្គមរបស់ខ្លួន មុនខែ សីហា ឆ្នាំ ២០១០ កន្លងមកត្រូវផ្តល់ព័ត៌មានជូនមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទារាជធានី ខេត្ត ពីឈ្មោះអ្នកទិញ ឬទទួលបញ្ចាំ ដើម្បីសម្រួលជូន ។

៦-មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទារាជធានី ខេត្ត ត្រូវសហការជាមួយសមាគមអតីតយុទ្ធជនកម្ពុជា និងសមាគមអតីតមន្ត្រីរាជការស៊ីវិលរាជធានី ខេត្ត បំផុសដល់មុខសញ្ញា ចូលរួមសហការក្នុងការអនុវត្តគោលការណ៍នេះ ដើម្បីជីវភាពរស់នៅរបស់បងប្អូន ។ ដោយឡែក ចំពោះអតីតយុទ្ធជន ត្រូវសហការល្អក្នុងការប្រើប្រាស់បេឡាឥណទាន ដើម្បីដោះស្រាយករណីនេះក្នុងក្របខណ្ឌសមាគមអតីតយុទ្ធជនកម្ពុជា ។

៧-មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទារាជធានី ខេត្ត ត្រូវត្រៀមបម្រុងថវិកាមួយចំនួន សម្រាប់ដោះស្រាយបញ្ហានេះ ឱ្យបានចប់សព្វគ្រប់នៅក្នុងឆ្នាំ ២០១០ ។ ក្រោយឆ្នាំ ២០១០ បើនៅមានសេសសល់កិច្ចការនេះកន្លែងណានោះ ប្រធានមន្ទីរ និងមន្ត្រីទទួលបន្ទុក នៃមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទារាជធានី ខេត្តនោះនឹងទទួលខុសត្រូវចំពោះមុខក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ។

៨-អគ្គាធិការ និងនាយកដ្ឋានសវនកម្មផ្ទៃក្នុង ត្រូវចុះធ្វើអធិការកិច្ចចំពោះការអនុវត្តភារកិច្ចនេះឱ្យបានហ្មត់ចត់ ។

៩-ខុទ្ទកាល័យរដ្ឋមន្ត្រី អគ្គនាយកនៃអគ្គនាយកដ្ឋានកិច្ចការរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានបច្ចេកទេស នាយកដ្ឋានសោធនអតីតយុទ្ធជន បេឡាជាតិអតីតយុទ្ធជន បេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល និងគ្រប់អង្គភាពពាក់ព័ន្ធត្រូវអនុវត្តសារាចរណែនាំនេះ ឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។៚

រដ្ឋមន្ត្រី

អ៊ិត សំហេង

ចម្លងជូន :

-ទីស្តីការគណៈរដ្ឋមន្ត្រី
-ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
-ក្រសួង ស្ថាប័ន ពាក់ព័ន្ធ
-គ្រប់សាលារាជធានី ខេត្ត
-ដូចចំណុច ៨ និង ៩
-ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ០០៥៧ ពណ.ចបព

ភ្នំពេញថ្ងៃទី ០៥ ខែមករា ឆ្នាំ ២០១០

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

សូមបញ្ជាក់ថា :

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅតាមលក្ខខណ្ឌដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុន : **អេចខេអេស (ខេមបូឌា) អ៊ីមផត & អិចផត**

HKS (CAMBODIA) IMPORT & EXPORT Co., Ltd.

អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : Co. ១៤៣៧៨/O៩ P ចុះថ្ងៃទី ២៣ ខែ ធ្នូ ឆ្នាំ ២០០៩

មានទម្រង់ទ្រាយជា : សហគ្រាសឯកបុគ្គលទទួលខុសត្រូវមានកម្រិត

២- អភិបាលក្រុមហ៊ុន : លោក **ហុង ពិសិដ្ឋ** ប្រធានក្រុមប្រឹក្សាភិបាល

លោក **ម៉ុង លីដេង** "តតិយជន" អភិបាល

៣- ដើមទុនក្រុមហ៊ុន : ចំនួន ២០.០០០.០០០ រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : លេខ ១៨ DEo ផ្លូវលេខ ២១៩ សង្កាត់ផ្សារដេប៉ូទី១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ។

៥- កម្មវត្ថុអាជីវកម្ម : -ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរ័ណ អាហរ័ណទំនិញគ្រប់ប្រភេទ ពិសេសលក់គ្រឿងបន្លាស់រថយន្តគ្រប់ប្រភេទ-នាំចូលឱសថ សំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ

-ការជួលដាក់ឃ្លាំងនូវផលិតផល ទំនិញគ្រប់ប្រភេទ -ការជួសជុលសំភារៈ ទំនិញគ្រប់ប្រភេទ

-ទិញ លក់ ជួល បញ្ចាំមូលនីធិពាណិជ្ជកម្ម-ទិញ លក់ ជួល ដីធ្លី ផ្ទះសំបែង

-ប្តូរប្រាក់ ផលិត ទិញ លក់ គ្រឿងអលង្ការ

-មន្ទីរពេទ្យពិគ្រោះព្យាបាលជម្ងឺ

-បើកសាលារៀន

-ភ្នាក់ងារពាណិជ្ជកម្ម -តំណាងពាណិជ្ជកម្ម

-សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម

-សេវាផ្សាយពាណិជ្ជកម្ម

-បោះពុម្ពផ្សាយ

-ផលិតខ្សែភាពយន្ត វីដេអូ CD

-ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស -សេវាបញ្ជូន និងចែកចាយទំនិញ

-សេវាយកកំរៃជើងសារលើការដឹកជញ្ជូន
-សាងសង់ ជួសជុល អាគារ ស្ពាន ថ្នល់
-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត
-វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ
-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម ។

៦- ថេរវេលា : ៩៩ ឆ្នាំ

រាល់ដំណាច់ឆ្នាំនីមួយៗ អភិបាលក្រុមហ៊ុនមានកាតព្វកិច្ចមកតម្កល់ប្រតិវេទន៍ប្រចាំឆ្នាំដែលទាក់ទងទៅនឹងស្ថានភាពរបស់ក្រុមហ៊ុននៅនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្មនៃក្រសួងពាណិជ្ជកម្ម ។

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬស្ថាប័នដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់ក្រុមហ៊ុន ពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។

ធេសរដ្ឋមន្ត្រី

ជ. រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

អនុរដ្ឋលេខាធិការ

ហ៊ូ-សារ៉ាន់

ចម្លងជូន

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួង ការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ធនាគារជាតិ នៃកម្ពុជា
- ក្រសួងសុខាភិបាល
- ក្រសួងទេសចរណ៍
- ក្រសួងពត៌មាន
- ក្រសួងអប់រំយុវជន និងកីឡា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- ក្រសួងកសិកម្ម រុក្ខា ប្រម៉ាញ់ និងនេសាទ
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- អគ្គនាយកដ្ឋានរាជកិច្ច និងសេវាកុំព្យូទ័រ
- សាលារាជធានីភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានីភ្នំពេញ "មុខការ"
- ឯកសារ -កាលប្បវត្តិ

ក ស ន

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ០០៦០ **ពណ.ចបព**

ភ្នំពេញថ្ងៃទី ០៥ **ខែ** កក្កដា **ឆ្នាំ** ២០១០

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

សូមបញ្ជាក់ថា :

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅតាមលក្ខខណ្ឌដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុន : **ឈាវ ស៊ីន អេនធើប្រាយ**

CHIAO SHEEN ENTERPRISE Co., Ltd.

អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : **Co. ១៤៣៩៥/០៩ P** ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ២០០៩

មានទ្រង់ទ្រាយជា : សហគ្រាសឯកបុគ្គលទទួលខុសត្រូវមានកម្រិត

២- អភិបាលក្រុមហ៊ុន : លោក **យូ សុគន្ធ**

៣- ដើមទុនក្រុមហ៊ុន : ចំនួន ៤.០០០.០០០.០០០ រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : លេខ ១៨ D ផ្លូវលេខ ៥១ CC សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ ។

៥- កម្មវត្ថុអាជីវកម្ម : -ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរ័ណ អាហរ័ណទំនិញគ្រប់ប្រភេទ នាំចូលឱសថ សំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ

-ការជួលដាក់ឃ្លាំងទុកផលិតផល ទំនិញគ្រប់ប្រភេទ -ការដំឡើងសំភារៈ ទំនិញគ្រប់ប្រភេទ

-ទិញ លក់ ជួល បញ្ចាំមូលនិធិពាណិជ្ជកម្ម -ទិញ លក់ ជួល ដីធ្លី ផ្ទះសំបែង

-ប្តូរប្រាក់ ផលិត ទិញ លក់ គ្រឿងអលង្ការ

-មន្ទីរពេទ្យពិគ្រោះព្យាបាលជម្ងឺ

-បើកសាលារៀន

-ភ្នាក់ងារពាណិជ្ជកម្ម -តំណាងពាណិជ្ជកម្ម

-សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ និងពាណិជ្ជកម្ម

-សេវាផ្សព្វផ្សាយពាណិជ្ជកម្ម

-ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស -សេវាបញ្ជូន និងចែកចាយទំនិញ

-សេវាយកកំរៃជើងសារលើការដឹកជញ្ជូន

-សាងសង់ ដំឡើង អាគារ ស្ពាន ថ្នល់

-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត

-វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ

-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម

៦- ថេរវេលា : ៩៩ ឆ្នាំ

រាល់ដំណាច់ឆ្នាំនីមួយៗ អភិបាលក្រុមហ៊ុនមានកាតព្វកិច្ចមកតំកល់ប្រតិវេទន៍ប្រចាំឆ្នាំ ដែលទាក់ទងទៅនឹងស្ថានភាពរបស់ក្រុមហ៊ុន នៅនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម នៃក្រសួងពាណិជ្ជកម្ម ។

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬស្ថាប័ន ដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់ក្រុមហ៊ុនពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។

ទេសរដ្ឋមន្ត្រី

ជ.រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

អនុរដ្ឋលេខាធិការ

ហ៊ូ-សារ៉ាន់

ចម្លងជូន

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងទេសចរណ៍
- ក្រសួងសុខាភិបាល
- ក្រសួងពត៌មាន
- ធនាគារជាតិនៃកម្ពុជា
- ក្រសួងអប់រំយុវជន និងកីឡា
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- ក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- អគ្គនាយកដ្ឋានរាជកិច្ច និងសេវាកុំព្យូទ័រ
- សាលារាជធានីភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានីភ្នំពេញ "មុខការ"
- ឯកសារ -កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ០០៦៦ ពណ.ចបព

ភ្នំពេញថ្ងៃទី ០៥ ខែមករា ឆ្នាំ ២០១០

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

សូមបញ្ជាក់ថា ៖

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅតាមលក្ខខណ្ឌដូចខាងក្រោម ៖

១- នាមករណ៍របស់ក្រុមហ៊ុន : **ខ្វលឡីធី គ្លូបឹល (ខេមបូឌា)**
QUALITY GLOBAL (CAMBODIA) Co., Ltd.

អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : Co. ៦៣៥៩/O៩ E ចុះថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ២០០៩

មានទ្រង់ទ្រាយជា : ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត

២- អភិបាលក្រុមហ៊ុន : លោក CHEAH CHUAN CHOON ប្រធានក្រុមប្រឹក្សាភិបាល
លោក **លេង ម៉ុល** អភិបាល

៣- ដើមទុនក្រុមហ៊ុន : ចំនួន ២០.០០០.០០០ រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : លេខ ៣០៦ ផ្លូវលេខ ២៦៥ សង្កាត់ទឹកល្អក់ទី២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ។

៥- កម្មវត្ថុអាជីវកម្ម : -ពាណិជ្ជកម្ម ៖ ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរ័ណ អាហរ័ណទំនិញគ្រប់ប្រភេទ នាំចូលឱសថ សំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ
-ការជួលដាក់ឃ្លាំងទុវផលិតផល ទំនិញគ្រប់ប្រភេទ -ការជួសជុលសំភារៈ ទំនិញគ្រប់ប្រភេទ
-ប្តូរប្រាក់ ផលិត ទិញ លក់គ្រឿងអលង្ការ
-មន្ទីរពេទ្យពិគ្រោះព្យាបាលជម្ងឺ
-បើកសាលារៀន
-ភ្នាក់ងារពាណិជ្ជកម្ម -តំណាងពាណិជ្ជកម្ម
-សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម
-សេវារកការងារជូនអតិថិជនធ្វើក្នុងនិងក្រៅប្រទេស
-សេវាផ្សាយពាណិជ្ជកម្ម
-បោះពុម្ពផ្សាយ
-ផលិតខ្សែភាពយន្ត វីដេអូ CD
-ដឹកជញ្ជូន ៖ ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស -សេវាបញ្ជូន និងចែកចាយទំនិញ
-សេវាយកតំរែរជើងសារលើការដឹកជញ្ជូន
-សាងសង់ ជួសជុល អាគារ ស្ពាន ថ្នល់...

-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត

-វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ

-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម ។

៦- ថេរវេលា : ៩៩ ឆ្នាំ

រាល់ដំណាច់ឆ្នាំនីមួយៗ អភិបាលក្រុមហ៊ុនមានកាតព្វកិច្ចមកតំកល់ប្រតិវេទន៍ប្រចាំឆ្នាំ ដែលទាក់ទងទៅនឹងស្ថានភាពរបស់ក្រុមហ៊ុន នៅនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម នៃក្រសួងពាណិជ្ជកម្ម ។

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬស្ថាប័ន ដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់ក្រុមហ៊ុនពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។

ធេសរដ្ឋមន្ត្រី

ជ. រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

អនុរដ្ឋលេខាធិការ

ហួ-សារ៉ាន់

ចម្លងជូន

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងទេសចរណ៍
- ក្រសួងសុខាភិបាល
- ក្រសួងពត៌មាន
- ធនាគារជាតិនៃកម្ពុជា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងអប់រំយុវជន និងកីឡា
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- ក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- អគ្គនាយកដ្ឋានរាជកិច្ច និងសេវាកុំព្យូទ័រ
- សាលារាជធានីភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានីភ្នំពេញ " មុខការ "
- ឯកសារ -កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ០០៦២ ពណ.ចបព

ភ្នំពេញថ្ងៃទី ០៥ ខែមករា ឆ្នាំ ២០១០

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

សូមបញ្ជាក់ថា ៖

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅតាមលក្ខខណ្ឌដូចខាងក្រោម ៖

១- នាមករណ៍របស់ក្រុមហ៊ុន : **យូនីខន មេនផៅវ័រ ខូ អិលធីឌី**
UNICORN MANPOWER CO., LTD.
អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : Co. ៦៣៧៨/O៩ E ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ២០០៩
មានទ្រង់ទ្រាយជា : ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត

២- អភិបាលក្រុមហ៊ុន : លោក TOK CHIT SING ប្រធានក្រុមប្រឹក្សាភិបាល
លោក TOK CHIT KONG អភិបាល

៣- ដើមទុនក្រុមហ៊ុន : ចំនួន ២០.០០០.០០០ រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : លេខ ១០៥ F ផ្លូវលេខ ២០០ សង្កាត់បឹងរាំង ខណ្ឌដូនពេញ រាជធានីភ្នំពេញ ។

៥- កម្មវត្ថុអាជីវកម្ម :
-សេវារកការងារជូនអតិថិជនធ្វើក្នុងនិងក្រៅប្រទេស
-បើកសាលារៀន និងមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ
-ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរណ៍ អាហរណទំនិញ -និងនាំចូលឱសថ សំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ
-ការជួលដាក់ឃ្លាំងទូវផលិតផល ទំនិញគ្រប់ប្រភេទ -ការជួសជុលសំភារៈ ទំនិញគ្រប់ប្រភេទ
-ប្តូរប្រាក់ ផលិត ទិញ លក់គ្រឿងអលង្ការ
-មន្ទីរពេទ្យពិគ្រោះនិងព្យាបាលជម្ងឺ
-ភ្នាក់ងារពាណិជ្ជកម្ម -តំណាងពាណិជ្ជកម្ម
-សេវាបោះពុម្ពផ្សាយ
-សេវាផ្សាយពាណិជ្ជកម្ម
-ផលិតខ្សែភាពយន្ត វីដេអូ CD
-ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស -សេវាបញ្ជូនទំនិញ និងថែក្សាយទំនិញ
-សេវាយកកំរៃជើងសារលើការដឹកជញ្ជូន
-សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម និងទេសចរណ៍
-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន ផ្ទះសំណាក់ មជ្ឈមណ្ឌលកំសាន្ត

-សាងសង់ ជួសជុល អាគារ ស្ពាន ថ្នល់ និងស្ថាបត្យកម្មគ្រប់ប្រភេទ

-វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ

-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម ។

៦- ថេរវេលា : ៩៩ ឆ្នាំ

រាល់ដំណាច់ឆ្នាំនីមួយៗ អភិបាលក្រុមហ៊ុនមានកាតព្វកិច្ចមកតំកល់ប្រតិវេទន៍ប្រចាំឆ្នាំ ដែលទាក់ទងទៅនឹងស្ថានភាពរបស់ក្រុមហ៊ុន នៅនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម នៃក្រសួងពាណិជ្ជកម្ម ។

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬស្ថាប័ន ដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់ក្រុមហ៊ុនពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។

ទេសរដ្ឋមន្ត្រី

ជ. រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

អនុរដ្ឋលេខាធិការ

ហ៊ូ-សារ៉ាន់

<u>ចម្លងជូន</u>

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងទេសចរណ៍
- ក្រសួងសុខាភិបាល
- ក្រសួងពត៌មាន
- ធនាគារជាតិនៃកម្ពុជា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងអប់រំយុវជន និងកីឡា
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- ក្រសួងកសិកម្មរុក្ខាប្រម៉ាញ់ និងនេសាទ
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- អគ្គនាយកដ្ឋានរាជកិច្ច និងសេវាកុំព្យូទ័រ
- សាលារាជធានីភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានីភ្នំពេញ " មុខការ "

៥.៨ - ឯកសារ -កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ០០៦៣ ពណ.ចបព

ភ្នំពេញថ្ងៃទី ០៦ ខែមករា ឆ្នាំ ២០១០

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

សូមបញ្ជាក់ថា :

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ តាមលក្ខខណ្ឌដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុន : **ហ្គ្រីន សឹលូសិន ត្រេឌីង**

GREEN SOLUTION TRADING Co., Ltd.

អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : Co. ១៩៣៣៥/០៩P ចុះថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ ២០០៩
មានទ្រង់ទ្រាយជា : ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត

២- អភិបាលក្រុមហ៊ុន : លោក ** យ៉ែន ស្រ៊ន់** ប្រធានក្រុមប្រឹក្សាភិបាល
លោក **គីម មុំហេង** អភិបាល

៣- ដើមទុនក្រុមហ៊ុន : ចំនួន ២០.០០០.០០០ រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : លេខ ៨៩ ផ្លូវម៉ាស៊ីនទឹក សង្កាត់ជ្រោយចង្វា ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ។

៥- កម្មវត្ថុអាជីវកម្ម :
-ពាណិជ្ជកម្ម :ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរ័ណ អាហរ័ណទំនិញគ្រប់ប្រភេទ នាំចូលឱសថ សំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ
-ការជួលដាក់ឃ្លាំងនូវផលិតផល ទំនិញគ្រប់ប្រភេទ -ការជួសជុលសំភារៈ ទំនិញគ្រប់ប្រភេទ
-ទិញ លក់ ជួល បញ្ចាំមូលនីធិពាណិជ្ជកម្ម-ទិញ លក់ ជួល ដីធ្លី ផ្ទះសំបែង
-ប្តូរប្រាក់ ផលិត ទិញ លក់ គ្រឿងអលង្ការ
-មន្ទីរពេទ្យពិគ្រោះព្យាបាលជម្ងឺ
-បើកសាលារៀន
-ភ្នាក់ងារពាណិជ្ជកម្ម -តំណាងពាណិជ្ជកម្ម
-សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម
-សេវាផ្សាយពាណិជ្ជកម្ម
-បោះពុម្ពផ្សាយ
-ផលិតខ្សែភាពយន្ត វីដេអូ CD
-ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស -សេវាដឹកជញ្ជូន និង ចែកចាយទំនិញ
-សេវាយកកំរៃជើងសារលើការដឹកជញ្ជូន
-សាងសង់ ជួសជុល អាគារ ស្ពាន ថ្នល់

-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត

-វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ

-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម ។

៦- ថេរវេលា : ៩៩ ឆ្នាំ

រាល់ដំណាច់ឆ្នាំនីមួយៗ អភិបាលក្រុមហ៊ុនមានកាតព្វកិច្ចមកតំកល់ប្រតិវេទន៍ប្រចាំឆ្នាំដែលទាក់ទងទៅនឹងស្ថានភាពរបស់ក្រុមហ៊ុននៅនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្មនៃក្រសួងពាណិជ្ជកម្ម ។

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬស្ថាប័នដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់ក្រុមហ៊ុនពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។

ជ. ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ប.ក

រដ្ឋលេខាធិការ

គីម ស៊ីថន

ចម្លងជូន

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួង ការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសុខាភិបាល
- ក្រសួងទេសចរណ៍
- ក្រសួងពត៌មាន
- ធនាគារជាតិ នៃកម្ពុជា
- ក្រសួងអប់រំយុវជន និងកីឡា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- ក្រសួងកសិកម្ម រុក្ខា ប្រម៉ាញ់ និងនេសាទ
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- អគ្គនាយកដ្ឋានរាជកិច្ច និង សេវាកុំព្យូទ័រ
- សាលារាជធានីភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានីភ្នំពេញ "មុខការ"
- ឯកសារ -កាលប្បវត្តិ

កសន

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce

ភ្នំពេញថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០១០

លេខ ០០៧៦ ពណ.ចបព

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

សូមបញ្ជាក់ថា ៖

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅតាមលក្ខខណ្ឌដូចខាងក្រោម ៖

១- នាមករណ៍របស់ក្រុមហ៊ុន : **អូខេ កុំព្យូទ័រ ស៊ីស្ទឹម គ្រុប អិលធីឌី**
OK COMPUTER SYSTEM GROUP LTD.

អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : Co. ១៤៣៧៥/O៩ P ចុះថ្ងៃទី ២២ ខែ ធ្នូ ឆ្នាំ ២០០៩

មានទ្រង់ទ្រាយជា : សហគ្រាសឯកបុគ្គលទទួលខុសត្រូវមានកម្រិត

២- អភិបាលក្រុមហ៊ុន : លោក **ចាន់ ស៊ូនីន**

៣- ដើមទុនក្រុមហ៊ុន : ចំនួន ២០.០០០.០០០ រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : លេខ ៣២ ផ្លូវលេខ ១៩៥ សង្កាត់ទំនប់ទឹក ខណ្ឌចំការមន រាជធានីភ្នំពេញ ។

៥- កម្មវត្ថុអាជីវកម្ម :
-សេវាតំឡើង និងជួសជុលប្រព័ន្ធកុំព្យូទ័រ និងគ្រឿងអេឡិចត្រូនិកគ្រប់ប្រភេទ
-ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរណ៍ អាហរណ៍ទំនិញគ្រប់ប្រភេទ ពិសេស សំភារៈបរិក្ខារអគ្គិសនី និងអេឡិចត្រូនិច -នាំចូលឱសថ សំភារៈបរិក្ខារ ពេទ្យគ្រប់ប្រភេទ
-ការជួលដាក់ឃ្លាំងទូវផលិតផល ទំនិញគ្រប់ប្រភេទ -ការជួសជុលសំភារៈ ទំនិញគ្រប់ប្រភេទ
-ទិញ លក់ ជួល បញ្ចាំមូលនិធិពាណិជ្ជកម្ម -ទិញ លក់ ជួល ដីធ្លី ផ្ទះសំបែង
-ប្តូរប្រាក់ ផលិត ទិញ លក់ គ្រឿងអលង្ការ
-មន្ទីរពេទ្យពិគ្រោះព្យាបាលជម្ងឺ
-បើកសាលារៀន
-ភ្នាក់ងារពាណិជ្ជកម្ម -តំណាងពាណិជ្ជកម្ម
-សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម
-សេវាផ្សាយពាណិជ្ជកម្ម
-បោះពុម្ពផ្សាយ
-ផលិតខ្សែភាពយន្ត វីដេអូ CD
-ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស -សេវាបញ្ជូន និងថែរក្សាទំនិញ
-សេវាយកពន្ធរដើងសារលើការដឹកជញ្ជូន
-សាងសង់ ជួសជុល អាគារ ស្ពាន ថ្នល់
-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត

-វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ

-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម ។

៦- ថេរវេលា : ៩៩ ឆ្នាំ

រាល់ដំណាច់ឆ្នាំនីមួយៗ អភិបាលក្រុមហ៊ុនមានកាតព្វកិច្ចមកតំកល់ប្រតិវេទនីប្រចាំឆ្នាំ ដែលទាក់ទងទៅនឹងស្ថានភាពរបស់ក្រុមហ៊ុន នៅនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម នៃក្រសួងពាណិជ្ជកម្ម ។

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬស្ថាប័ន ដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់ក្រុមហ៊ុនពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។

ជ. ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

រដ្ឋលេខាធិការ

គឹម_ស៊ីថន

ចម្លងជូន

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងទេសចរណ៍
- ក្រសួងសុខាភិបាល
- ក្រសួងពត៌មាន
- ធនាគារជាតិនៃកម្ពុជា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងអប់រំយុវជន និងកីឡា
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- ក្រសួងកសិកម្មរុក្ខាប្រម៉ាញ់ និងនេសាទ
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- អគ្គនាយកដ្ឋានរាជកិច្ច និងសេវាកុំព្យូទ័រ
- សាលារាជធានីភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានីភ្នំពេញ " មុខការ "
- ឯកសារ -កាលប្បវត្តិ

ស.៩

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ០០៧៧ ពណ.ចបព

ភ្នំពេញថ្ងៃទី ០៨ ខែមករា ឆ្នាំ ២០១០

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

សូមបញ្ជាក់ថា :

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ តាមលក្ខខណ្ឌដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុន : **អូតូ លីហ្វ**

AUTO LIFT Co., Ltd.

អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : **Co. ១៤២៤៦/០៩P** ចុះថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ២០០៩

មានទ្រង់ទ្រាយជា : សហគ្រាសឯកបុគ្គលទទួលខុសត្រូវមានកម្រិត

២- អភិបាលក្រុមហ៊ុន : លោក **អ៊ី សុខគា**

៣- ដើមទុនក្រុមហ៊ុន : ចំនួន ២០.០០០.០០០ រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : លេខ ៦៣៥ ផ្លូវជាតិលេខ ៥ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ។

៥- កម្មវត្ថុអាជីវកម្ម : -ពាណិជ្ជកម្ម :ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហ៊ែរណៃ អាហារណទំនិញគ្រប់ប្រភេទ- ទិញ លក់ តម្លើង និងជួសជុលជណ្តើរយន្តគ្រប់ប្រភេទ- នាំចូលឱសថ សំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ

-ការជួលដាក់ឃ្លាំងទុកផលិតផល ទំនិញគ្រប់ប្រភេទ -ការជួសជុលសំភារៈ ទំនិញគ្រប់ប្រភេទ

-ទិញ លក់ ជួល បញ្ចាំមូលនីធិពាណិជ្ជកម្ម-ទិញ លក់ ជួល ដីធ្លី ផ្ទះសំបែង

-ប្តូរប្រាក់ ផលិត ទិញ លក់ គ្រឿងអលង្ការ

-មន្ទីរពេទ្យពិគ្រោះព្យាបាលជម្ងឺ

-បើកសាលារៀន

-ភ្នាក់ងារពាណិជ្ជកម្ម -តំណាងពាណិជ្ជកម្ម

-សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម

-សេវារកការងារជូនអតិថិជនធ្វើក្នុង និងក្រៅប្រទេស

-សេវាផ្នែកពត៌មានវិទ្យា

-សេវាផ្សាយពាណិជ្ជកម្ម

-បោះពុម្ពផ្សាយ

-ផលិតខ្សែភាពយន្ត វីដេអូ CD

-ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស -សេវាបញ្ចេញ និង ចែកចាយទំនិញ

-សេវាយកគំរូរជើងសារលើការដឹកជញ្ជូន

-សាងសង់ ជួសជុល អាគារ ស្ពាន ថ្នល់
-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត
-វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ
-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម ។

៦- ថេរវេលា : ៩៩ ឆ្នាំ

រាល់ដំណាច់ឆ្នាំនីមួយៗ អភិបាលក្រុមហ៊ុនមានកាតព្វកិច្ចមកតំកល់ប្រតិវេទន៍ប្រចាំឆ្នាំដែលទាក់ទងទៅនឹងស្ថានភាពរបស់ក្រុមហ៊ុននៅនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្មនៃក្រសួងពាណិជ្ជកម្ម ។

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬស្ថាប័នដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់ក្រុមហ៊ុនពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។

ជ. ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

រដ្ឋលេខាធិការ

គឹម ស៊ីថន

ចម្លងជូន

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួង ការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសុខាភិបាល
- ក្រសួងទេសចរណ៍
- ក្រសួងពត៌មាន
- ធនាគារជាតិ នៃកម្ពុជា
- ក្រសួងអប់រំយុវជន និងកីឡា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- ក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- អគ្គនាយកដ្ឋានរាជកិច្ច និង សេវាកុំព្យូទ័រ
- សាលារាជធានីភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានីភ្នំពេញ "មុខការ"
- ឯកសារ -កាលប្បវត្តិ

កសឧ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ០០៦៤ ពណ.ចបព

ភ្នំពេញថ្ងៃទី ០៦ ខែ សីហា ឆ្នាំ ២០១០

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

សូមបញ្ជាក់ថា :

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ តាមលក្ខខណ្ឌដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុន : **អ៊ី ~ ធេល ខមម្យូនីខេសិន សឺវីស**
e - Tel Communication Service Co., Ltd

អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : **Co. ១៤៣២២/០៩ P** ចុះថ្ងៃទី ០២ ខែ ធ្នូ ឆ្នាំ ២០០៩

មានទ្រង់ទ្រាយជា : សហគ្រាសឯកបុគ្គលទទួលខុសត្រូវមានកម្រិត

២- អភិបាលក្រុមហ៊ុន : លោក **នេន ហ៊្វ**

៣- ដើមទុនក្រុមហ៊ុន : ចំនួន ២០.០០០.០០០ រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : លេខ ៥២ ផ្លូវលេខ ៧៧ BT សង្កាត់បឹងទំពុន ខណ្ឌមានជ័យ រាជធានីភ្នំពេញ

៥- កម្មវត្ថុអាជីវកម្ម : -សេវាផ្នែកពត៌មានវិទ្យា -អ៊ិនធើណេត
-ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរ័ណ អាហរ័ណទំនិញគ្រប់ប្រភេទ នាំចូលសំភារៈបរិក្ខារទូរគមនាគមន៍ ឱសថ សំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ
-ការជួលដាក់ឃ្លាំងទូវផលិតផល ទំនិញគ្រប់ប្រភេទ-ការជួសជុលសំភារៈ ទំនិញគ្រប់ប្រភេទ
-ទិញ លក់ ជួល បញ្ចាំមូលនីធិពាណិជ្ជកម្ម-ទិញ លក់ ជួល ដីធ្លី ផ្ទះសំបែង
-ប្តូរប្រាក់ ផលិត ទិញ លក់ គ្រឿងអលង្ការ
-មន្ទីរពេទ្យពិគ្រោះព្យាបាលជម្ងឺ
-បើកសាលារៀន
-ភ្នាក់ងារពាណិជ្ជកម្ម -តំណាងពាណិជ្ជកម្ម
-សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម
-សេវាផ្សាយពាណិជ្ជកម្ម
-បោះពុម្ពផ្សាយ
-ផលិតខ្សែភាពយន្ត វីដេអូ CD

-ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស -សេវាបញ្ជូន និងចែកចាយទំនិញ

-សេវាយកកំរៃជើងសារលើការដឹកជញ្ជូន

-សាងសង់ ជួសជុល អាគារ ស្ពាន ថ្នល់

-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត

-វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ

-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម

៦- ថេរវេលា : ៩៩ ឆ្នាំ

រាល់ដំណាច់ឆ្នាំនីមួយៗ អភិបាលក្រុមហ៊ុនមានកាតព្វកិច្ច មកតំកល់ប្រតិវេទន៍ប្រចាំឆ្នាំ ដែលទាក់ទងទៅនឹងស្ថានភាពរបស់ក្រុមហ៊ុន នៅនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម នៃក្រសួងពាណិជ្ជកម្ម ។

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬ ស្ថាប័ន ដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់ក្រុមហ៊ុន ពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។

ជ. ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

រដ្ឋលេខាធិការ

គីម_ស៊ីថន

ចម្លងជូន

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
-ក្រសួង ការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសុខាភិបាល
- ក្រសួងទេសចរណ៍
- ក្រសួងពត៌មាន
- ធនាគារជាតិនៃកម្ពុជា
- ក្រសួងអប់រំ យុវជន និងកីឡា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
-អគ្គនាយកដ្ឋានរាជកិច្ច និងសេវាកុំព្យូទ័រ
- សាលារាជធានីភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានីភ្នំពេញ "មុខការ"
- ឯកសារ -កាលប្បវត្តិ

ស.ម